# ព្រះពោធិសត្វ

## ភាគទី ៣



រៀបរៀងដោយ

ភិក្ខុបញ្ញាសីលោ

ភិក្ខុ ប៊ុត សាវង្ស

# ១~ ចុល្លពោធិជាតក

(បិដកលេខ ៥៩ , ទំព័រ ១៧៤-១៧៦ និងអដ្ឋកថា)

សម្តេចព្រះភគវា កាលដែលព្រះអង្គទ្រង់គង់ប្រថាប់នៅនាព្រះជេតពនមហាវិហារ ព្រះអង្គបានប្រារព្ធនូវភិក្ខុមួយអង្គដែលច្រើនទៅដោយសេចក្តីក្រោធ ទ្រង់បានត្រាស់នូវព្រះធម៌ទេសនានេះថា **យោ តេ ឥមំ វិសាលក្ខឹ** ដូច្នេះជាដើម ។

បានឮថា ភិក្ខុអង្គនោះ សូម្បីបួសនៅក្នុងព្រះពុទ្ធ-សាសនា ដែលជាសាសនានាំសត្វចេញចាកទុក្ខ ក៏មិនអាចដើម្បីនឹងគ្របសង្កត់នូវសេចក្តីក្រោធបាន លោកជាបុគ្គលដែលច្រើនទៅដោយសេចក្តីក្រោធ ច្រើនដោយការទាស់ចិត្ត គ្រាន់តែគេពោលស្តីឱ្យបន្តិចបន្តួច ក៏ក្រេវ-ក្រោធប្រទូស្តតប មានសភាពដូច្នេះឯង ។



ព្រះបរមសាស្តា ទ្រង់ជ្រាបថា ភិក្ខុអង្គនោះច្រើនដោយសេចក្តីក្រោធដូច្នេះហើយ ទើបព្រះអង្គត្រាស់ឱ្យហៅភិក្ខុនោះមក ហើយទ្រង់ត្រាស់សួរថា ម្នាលភិក្ខុបានឮថា លោកជាបុគ្គលច្រើនដោយសេចក្តីក្រោធពិតមែនឬ ? កាលដែលភិក្ខុនោះក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ពិតដូច្នោះមែន ទើបព្រះអង្គត្រាស់ថា ម្នាលភិក្ខុ ដែលឈ្មោះថាសេចក្តីក្រោធ លោកគួរតែហាមឃាត់វា ព្រោះសេចក្តីក្រោធដែលមានសភាពបែបនេះ នឹងធ្វើប្រយោជន៍ឱ្យក្នុងលោកនេះ និងក្នុងលោកខាងមុខនោះមិនមានឡើយ ។ លោកបួសក្នុងសាសនារបស់ព្រះពុទ្ធដែលមិនក្រោធហើយ ហេតុអ្វីបានជានៅតែក្រោធ ពិតណាស់ បណ្ឌិតទាំងឡាយពីបុរាណ សូម្បីបួសនៅក្នុងលទ្ធិក្រៅព្រះពុទ្ធសាសនា ក៏មិនធ្វើនូវសេចក្តីក្រោធដែរ។ រួចហើយ ទ្រង់នាំយករឿងក្នុងអតីតកាល មកសម្តែងដូចតទៅ :

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តគ្រងរាជ-

សម្បត្តិក្នុងនគរពារាណសី នាដែនកាសី មានព្រាហ្មណ៍ម្នាក់ ជាអ្នកមានភោគសម្បត្តិច្រើន ។ គ្រានោះ ព្រះបរមពោធិសត្វ ចុតិចាកព្រហ្មលោក មកបដិសន្ធិក្នុងផ្ទៃនៃនាងព្រាហ្មណី កាលដែលប្រសូតហើយ ពួកញាតិក៏បានដាក់ឈ្មោះថា **ពោធិកុមារ** ។ លុះពោធិកុមារចម្រើនវ័យហើយ ក៏ទៅនគរតក្កសិលា រៀនចប់សិល្បសាស្ត្រគ្រប់យ៉ាង ទើបត្រឡប់មកព្រះនគររបស់ខ្លួនវិញ ។ មាតាបិតា បាននាំកូនស្រីដែលមានត្រកូលស្មើគ្នាមកឱ្យ ទាំងដែលព្រះបរមពោធិសត្វ មិនមានការប្រាថ្នាសោះឡើយ ។ ចំណែកកូនស្រីនោះក៏ចុតិពីព្រហ្មលោកមកកើតដូចគ្នា មានរូបរាងកាយល្អល្អះ ប្រៀបដូចទេពអប្សរ ។ ទាំងពីរអង្គទោះជាមិនប្រាថ្នា ក៏ពួកញាតិចាត់ការ រៀបអាវាហវិវាហមង្គលឱ្យដែរ ។ អ្នកទាំងពីរនៅជាមួយគ្នាមិនមានវវើរវាយដោយកិលេសឡើយ សូម្បីគ្រាន់តែសម្លឹងមើលគ្នា ដោយអំណាចនៃរាគៈ ក៏មិនមានដែរ ឯចំណែកមេថុនធម្ម មិនធ្លាប់ជួបប្រសព្វ សូម្បីតែក្នុងការ



យល់សប្តិ ទាំងពីរនាក់ជាក់ជាមានសីលបរិសុទ្ធប្រាកដដោយប្រការដូច្នេះឯង ។

ក្រោយមក កាលដែលមាតាបិតាធ្វើកាលកិរិយាអស់ហើយ ព្រះបរមពោធិសត្វ បានហៅនាងជាភរិយាមកប្រាប់ថា ម្នាលនាងដ៏ចម្រើន នាងចូរទទួលទ្រព្យ ៨០ កោដិនេះ ទុកចិញ្ចឹមជីវិតឱ្យជាសុខចុះ ។ នាងជាភរិយាសួរថា ចុះចំណែកអ្នកជាម្ចាស់វិញនោះ ? ព្រះបរមពោធិសត្វតបថា ខ្ញុំមិនមានកិច្ចដោយទ្រព្យឡើយ ខ្ញុំនឹងចូលទៅកាន់ដែនដីព្រៃហិមពាន្ត បួសជាតាបសធ្វើទីពឹងដល់ខ្លួន។ នាងជាភរិយាសួរទៀតថា បពិត្រអ្នកជាម្ចាស់ បព្វជ្ជានោះគួរដល់តែពួកបុរសទេឬ ? ព្រះបរមពោធិសត្វតបថា សូម្បីពួកស្ត្រីក៏គួរដែរណ៎ា! នាងដ៏ចម្រើន ។ ភរិយាទើបពោលថា បើដូច្នោះ ខ្ញុំម្ចាស់មិនទទួលទឹកកំហាកដែលអ្នកជាម្ចាស់ខាកស្តោះចោលនោះទេ សូម្បីខ្ញុំក៏មិនមានកិច្ចដោយទ្រព្យដែរ ខ្ញុំម្ចាស់នឹងបួសជាមួយអ្នកជាម្ចាស់ដែរ ។ ព្រះបរមពោធិសត្វក៏ទទួលថា សាធុ! សាធុ!

ល្អហើយម្នាលនាងដ៏ចម្រើន ។ អ្នកទាំងពីរបានឱ្យមហាទាន ហើយចេញទៅសាងអាស្រម ក្នុងភូមិប្រទេសដ៏ជាទីរីករាយ ។ បួសហើយក៏ស្វែងរកផលាផលចិញ្ចឹមជីវិតក្នុងទីនោះរហូតដល់ ១០ ឆ្នាំ តែឈានសមាបត្តិមិនបានកើតឡើងដល់លោកទាំងពីរឡើយ គឺឥសីទាំងពីរនៅក្នុងទីនោះ ១០ ឆ្នាំ បានសុខដែលកើតអំពីបព្វជ្ជាតែប៉ុណ្ណោះ ។ ដើម្បីសេពសោយនូវរសប្រៃជាដើម ទើបត្រាច់ចារិកទៅតាមជនបទ ដល់ព្រះនគរពារាណសីដោយលំដាប់ ហើយអាស្រ័យនៅក្នុងព្រះរាជឧទ្យាន ។

ថ្ងៃមួយ ព្រះរាជាទតព្រះនេត្រឃើញបុរសអ្នករក្សាសួន កាន់គ្រឿងបណ្ណាការមកគាល់ ទើបត្រាស់ថា យើងនឹងទៅកម្សាន្តសួន អ្នកចូរជម្រះផ្លូវហើយរៀបចំសួនឧទ្យានឱ្យស្អាត ។ ព្រះរាជា ស្ដេចទៅកាន់ព្រះរាជឧទ្យាន ដែលនាយឧទ្យានបាលនោះ សម្អាតរៀបរយល្អហើយ ព្រមដោយបរិវារដ៏ច្រើន ។ ខណៈនោះឥសីទាំងពីរ ក៏កំពុងតែគង់នៅក្នុងព្រះរាជឧទ្យានដែរ បាន



អង្គុយ ឱ្យកាលកន្លងទៅដោយសេចក្ដីសុខ ដែលកើតពីបព្វជ្ជា ។ ព្រះរាជា ស្ដេចកម្សាន្តព្រះរាជហឫទ័យក្នុងឧទ្យាន បានទតព្រះនេត្រឃើញឥសីទាំងពីរនោះ កាលដែលទ្រង់សម្លឹងមើលនាងបរិព្វាជិកា ដែលមានរូបរាងល្អអស្ចារ្យ ក៏កើតតម្រេក មានហឫទ័យប្រតិព័ទ្ធ ។ ព្រះអង្គញាប់ញ័រដោយអំណាចនៃកិលេស ទ្រង់ព្រះតម្រិះថា យើងនឹងសាកសួរមើលសិន តើនាងបរិព្វាជិកានេះ ត្រូវជាអ្វីនឹងព្រះតាបសនេះ រួចហើយទ្រង់ក៏ចូលទៅរកព្រះបរមពោធិសត្វ ត្រាស់សួរថា បពិត្របព្វជិត នាងបរិព្វាជិកានេះ ត្រូវជាអ្វីជាមួយនឹងលោក ? ព្រះតាបសតបថា មហាបពិត្រ មិនបានជាអ្វីនឹងគ្នាទេ គ្រាន់តែបួសជាមួយគ្នាតែប៉ុណ្ណោះ ប៉ុន្តែ កាលដែលនៅពីគ្រហស្ថ នាងគឺជាភរិយារបស់អាត្មាភាព ។ ព្រះរាជាទ្រង់ព្រះសណ្ដាប់ដូច្នេះហើយ ទ្រង់ព្រះតម្រិះថា នាងនេះមិនបានជាអ្វីនឹងព្រះតាបសនេះឡើយ តែជាភរិយាគ្រាដែលនៅពីគ្រហស្ថ ដូច្នេះកាលបើយើងនឹងនាំយកនាងនេះទៅ ដោយកម្លាំង

នៃភាពជាធំរបស់យើង តើព្រះតាបសនេះ នឹងធ្វើយ៉ាងណាហ្ន៎ យើងនឹងសួរសាកមើលសិន ។ រួចហើយព្រះរាជាទើបចូលទៅជិត ពោលនូវព្រះគាថាទី ១ ថា :

**យោ តេ ឥមំ វិសាលក្ខិំ បិយំ សម្មិល្លហាសិនិំ**
**អាទាយ ពលា គច្ឆេយ្យ កិំ នុ កយិរាសិ ព្រាហ្មណ។**

បើបុគ្គលណា ចាប់យកនាងបរិព្វាជិកា នាងមានមុខញញឹមស្រស់ថ្លា នេត្រាធំទូលាយ (ដូចរាយមន្តស្នេហ៍) គួរជាទីស្រឡាញ់នេះ ដែលនាងជារបស់អ្នក គឺចាប់ទៅដោយកម្លាំងពលក្ការ ម្នាលព្រាហ្មណ៍ តើអ្នកប្រាថ្នានឹងធ្វើអ្វី (ដល់បុគ្គលនោះ ) ។

បណ្ដាបទទាំងនោះ បទថា **សំសិលហាសិនិំ** [1] បានដល់អ្នកមានផ្ទៃមុខញញឹមតិចៗ ។

បទថា **ពលា គច្ឆេយ្យ** បានដល់នាំយកទៅដោយពលក្ការ (គំរាមកំហែង ) ។

បទថា **កិំ នុ កយិរាសិ** ដោយសេចក្ដីថា ម្នាល

១-បាលីបិដកថា **សម្មិល្លហាសិនិំ** ។



ព្រាហ្មណ៍ អ្នកនឹងធ្វើយ៉ាងណាដល់បុគ្គលនោះ ។

លំដាប់នោះ ព្រះបរមពោធិសត្វ បានស្ដាប់ព្រះតម្រាស់របស់ព្រះរាជាហើយ បានពោលនូវព្រះគាថាទី ២ ថា :

**ឧប្បជ្ជេ មេ ន មុច្ចេយ្យ ន មេ មុច្ចេយ្យ ជីវតោ**
**រជំវ វិបុលា វុដ្ឋិ ខិប្បមេវ និវារយេ ។**

សេចក្ដីក្រោធកើតឡើងដល់អាត្មា គឺចេញមកមិនបានឡើយ កាលអាត្មានៅមានជីវិត សេចក្ដីក្រោធចេញមកមិនបានទេ អាត្មាហាមឃាត់ដោយឆាប់រហ័ស ឱ្យដូចជាភ្លៀងធំរំងាប់នូវធូលី ។

គប្បីជ្រាបសេចក្ដីនៃព្រះគាថានេះដូច្នេះថា មហា-បពិត្រ កាលបើអ្នកណា នាំយកនាងនេះទៅ សេចក្ដីក្រោធគប្បីកើតឡើងដល់អាត្មាភាពនៅខាងក្នុង សេចក្ដីក្រោធនោះ កាលដែលកើតឡើងក្នុងអាត្មាភាពហើយ មិនចេញមកខាងក្រៅទេ នឹងមិនចេញមកឡើយ (គឺមិនចេញមកតាមផ្លូវកាយ ផ្លូវវាចានិងមុខមាត់អាកប្បកិរិយា ) ។

ដរាបណា ដែលអាត្មានៅមានជីវិត ដរាបនោះ អាត្មានឹងមិនឱ្យសេចក្តីក្រោធនោះ តាំងនៅក្នុងអាត្មាដោយការនៅរួមគ្នាឡើយ អាត្មានឹងគ្របសង្កត់ ហាមឃាត់ ដោយមេត្តាភាវនាយ៉ាងឆាប់រហ័ស ដូចភ្លៀងដែលមានគ្រាប់ធំៗ ជម្រះលាងធូលីដែលកើតឡើងហើយ យ៉ាងឆាប់រហ័ស ដូច្នោះឯង ។

ព្រះបរមពោធិសត្វ បានបន្លឺសីហនាទយ៉ាងនេះ ចំណែកព្រះរាជា សូម្បីទ្រង់បាននូវព្រះសណ្តាប់ពាក្យរបស់ព្រះបរមពោធិសត្វហើយក៏ដោយ ក៏មិនអាចនឹងហាមព្រះហឫទ័យរបស់ព្រះអង្គ ដែលទ្រង់ប្រតិព័ទ្ធបានឡើយ ។ ព្រះរាជាបានបង្គាប់អាមាត្យម្នាក់ថា អ្នកចូរនាំនាងបរិព្វាជិកានេះ ទៅកាន់ព្រះរាជនិវេសន៍ ។ អាមាត្យនោះទទួលនូវព្រះរាជបញ្ជាហើយ បាននាំនាងបរិព្វាជិកាទៅ ដែលនាងបានស្រែកយំ ទាំងដែលបានពោលថា អធម៌កំពុងប្រព្រឹត្តទៅក្នុងលោក មិនសមគួរឡើយ ដូច្នេះជាដើម ។ ព្រះបរមពោធិសត្វ ស្តាប់សំឡេងយំសោក



រៀបរាប់របស់នាង ហើយបានសម្លឹងមើលនាងត្រឹមតែម្តងប៉ុណ្ណោះ មិនបានមើលទៀតឡើយ នាងត្រូវបានពួករាជបុរសនាំយកទៅកាន់ព្រះរាជនិវេសន៍ ទាំងសម្រែកសោកសៅ ។ ស្តេចអន្ធពាល ក៏មិនបានបង្អង់ឱ្យយឺតយូរនៅនឹងព្រះរាជឧទ្យានឡើយ ទ្រង់ប្រញាប់ត្រឡប់ទៅកាន់ព្រះរាជវាំងវិញ ហើយត្រាស់បង្គាប់ឱ្យនាំយកនាងបរិព្វាជិកានោះមក ។ ព្រះរាជា បានលួងលោមដោយពាក្យស្នេហា និងបានសន្យាប្រគល់យស ឱ្យនាងខ្ពង់ខ្ពស់បានជាធំលើស្ត្រីទាំងឡាយ តែនាងបានពណ៌នានូវទោសរបស់យស និងរៀបរាប់នូវគុណរបស់បព្វជ្ជា រឿយៗជានិច្ច ។ ព្រះរាជាទ្រង់ប្រើវិធីសព្វគ្រប់ ក៏មិនអាចនឹងចងចិត្តនាងទុកបានឡើយ ។ ស្តេចទ្រង់ត្រាស់បង្គាប់ឱ្យឃុំឃាំងនាងក្នុងបន្ទប់ ហើយទ្រង់ព្រះតម្រិះថា នាងបរិព្វាជិកានេះ មានសីល មានកល្យាណធម៌ មិនប្រាថ្នានូវយសដែលមានសភាពបែបនេះឡើយ សូម្បីព្រះតាបសនោះ កាលដែលនាងបរិព្វាជិកាដ៏ស្អាតបែបនេះ ត្រូវចាប់

បង្ខំយកមក ក៏មិនបានសម្លឹងមើលដោយសេចក្ដីក្រោធដែរ ប៉ុន្តែ ធម្មតាបព្វជិតរមែងមានមាយាច្រើន ប្រកបអ្វីៗឡើង ដើម្បីធ្វើឱ្យយើងវិនាសក៏មិនដឹង យើងនឹងទៅមើលឱ្យដឹងសិនថា លោកកំពុងធ្វើអ្វី ។ ទ្រង់ព្រះតម្រិះដូច្នេះហើយ ក៏មិនអាចនៅយូរបានឡើយ ស្ដេចប្រញាប់យាងទៅព្រះរាជឧទ្យាន ។

ចំណែកព្រះបរមពោធិសត្វ កំពុងតែគង់នៅដេរចីវរ ព្រះរាជាព្រមដោយបរិវារតិចតួច ទ្រង់ចូលទៅស្ងាត់ៗ មិនឱ្យឮសំឡេងព្រះបាទឡើយ ។ ព្រះបរមពោធិ-សត្វ មិនបានសម្លឹងមើលព្រះរាជា ចេះតែដេរចីវរជាបន្តទៅ ។ ព្រះរាជាក៏យល់ខុសថា ព្រះតាបសនេះ មានសេចក្ដីក្រោធ ទើបមិនប្រស្រ័យជាមួយនឹងយើង ជាតាបសកោង មុនដំបូងអួតអាងថា នឹងមិនឱ្យសេចក្ដីក្រោធកើតឡើងឡើយ បើកើតឡើងក៏នឹងគ្របសង្កត់ដោយឆាប់រហ័យ តែឥឡូវនេះ ជាតាបសព្រហើនដោយសេចក្ដីក្រោធ មិននិយាយជាមួយនឹងយើង។ ដូច្នេះហើយ



ស្ដេចទើបត្រាស់នូវព្រះគាថាទី ៣ ថា :

**យន្នុ បុព្វេ វិកត្ថិតោ ពលម្ហិវ អបស្សិតោ**
**ស្វាជ្ជ តុណ្ហិកតោទានិ សង្ឃាដឹ សិព្វមច្ឆសិ ។**

ថ្ងៃមុនលោកនិយាយអួតអាង យ៉ាងណានោះហ្ន៎ ឥឡូវថ្ងៃនេះ លោកដូចជាអាងកម្លាំង ធ្វើជាមិនឃើញយើង ហើយនៅស្ងៀម សំងំដេរចីវរធ្វើសង្ឃាដីទៅវិញ។

ព្រះបរមពោធិសត្វ បានស្ដាប់ដូច្នេះ ទើបគិតថា ព្រះរាជាអង្គនេះ យល់ខុសចំពោះយើង ដែលយើងមិនប្រស្រ័យជាមួយនឹងព្រះអង្គ ថាយើងស្ងៀមដោយអំណាចនៃសេចក្ដីក្រោធ យើងនឹងទូលព្រះអង្គនូវសេចក្ដីដែលយើងមិនលុះក្នុងអំណាចនៃសេចក្ដីក្រោធដែលកើតឡើងឱ្យទ្រង់ជ្រាបក្នុងទីនេះ ហើយបានសម្ដែងនូវព្រះគាថាទី ៤ ថា :

**ឧប្បជ្ជិ មេ ន មុច្ចិត្ថ ន មេ មុច្ចិត្ថ ជីវតោ**
**រជំវ វិបុលា វុដ្ឋិ ខិប្បមេវ និវារយឹ ។**

សេចក្ដីក្រោធកើតឡើងដល់អាត្មា គឺចេញមកមិន

បានឡើយ កាលអាត្មានៅមានជីវិត សេចក្តីក្រោធចេញមកមិនបានទេ អាត្មាហាមឃាត់ដោយឆាប់រហ័ស ឱ្យដូចជាភ្លៀងធំរំងាប់នូវធូលី ។

ព្រះរាជា ទ្រង់ព្រះសណ្តាប់ដូច្នោះហើយ ទ្រង់ព្រះតម្រិះថា តាបសនេះនិយាយសំដៅចំពោះតែសេចក្តីក្រោធប៉ុណ្ណោះ ឬសំដៅដល់សិល្បៈអ្វីៗដទៃផង យើងនឹងសួរលោកសិន ។ កាលដែលទ្រង់ត្រាស់សួរ បានត្រាស់នូវព្រះគាថាទី ៥ ថា :

**កិន្តេ ឧប្បជ្ជិ នោ មុញ្ចិ    កិន្តេ ន មុញ្ចិ ជីវតោ**
**រជំវ វិបុលា វុដ្ឋិ    កតមំ តំ និវារយិ ។**

សេចក្តីក្រោធកើតឡើងដល់លោក គឺចេញមកមិនបាននោះ តើដូចម្តេច កាលលោកនៅមានជីវិត សេចក្តីក្រោធចេញមកមិនបាននោះ តើយ៉ាងណា ហើយលោកហាមឃាត់នូវសេចក្តីក្រោធ ដោយឆាប់រហ័ស ឱ្យដូចជាភ្លៀងធំរំងាប់នូវធូលីនោះ តើយ៉ាងណាដែរ ។

ព្រះបរមពោធិសត្វ បានស្តាប់ដូច្នោះហើយ ក៏បាន



ពោលថា មហាបពិត្រ សេចក្តីក្រោធ មានទោសដ៏ច្រើនសន្ធឹក ប្រកបដោយមហន្តរាយ ។ សេចក្តីក្រោធមួយបែបកើតដល់អាត្មាភាពហើយ តែអាត្មាភាពបានហាមឃាត់នូវសេចក្តីក្រោធ ដែលកើតឡើងហើយនោះ ដោយមេត្តាភាវនា ។ ដូច្នេះហើយ កាលដែលនឹងប្រកាសទោសនៃសេចក្តីក្រោធ ទើបពោលគាថា ទាំងអស់នេះថា :

**យម្ហិ ជាតេ ន បស្សតិ    អជាតេ សាធុ បស្សតិ**
**សោ មេ ឧប្បជ្ជិ នោ មុញ្ចិ    កោធោ ទុម្មេធគោចរោ។**

កាលសេចក្តីក្រោធកើតឡើងហើយ បុគ្គលរមែងមើលមិនឃើញនូវប្រយោជន៍របស់ខ្លួន និងប្រយោជន៍អ្នកដទៃឡើយ កាលបើសេចក្តីក្រោធមិនកើតឡើងទេ បុគ្គលទើបមើលឃើញបានដោយប្រពៃ សេចក្តីក្រោធនោះ កើតឡើងដល់អាត្មាភាពហើយ ចេញមកមិនបានឡើយ សេចក្តីក្រោធ ជាទីគោចររបស់បុគ្គលល្ងង់ខ្លៅ ។

**យេន ជាតេន នន្ទន្តិ    អមិត្តា ទុក្ខមេសិនោ**
**សោ មេ ឧប្បជ្ជិ នោ មុញ្ចិ    កោធោ ទុម្មេធគោចរោ។**

បុគ្គលទាំងឡាយដែលជាសត្រូវនឹងយើង ជាអ្នកស្វែងរកសេចក្តីទុក្ខឱ្យយើង រមែងត្រេកអរនឹងយើងដែលមានសេចក្តីក្រោធកើតឡើង (បុគ្គលអ្នកក្រោធ ជាសត្រូវដល់ខ្លួនឯង ស្វែងរកទុក្ខមកដាក់ខ្លួន) សេចក្តីក្រោធនោះកើតឡើងដល់អាត្មាភាពហើយ ចេញមកមិនបានឡើយ សេចក្តីក្រោធ ជាទីគោចររបស់បុគ្គលល្ងង់ខ្លៅ ។

**យស្មិញ្ច ជាយមានស្មឹ សទត្ថំ នាវពុជ្ឈតិ**
**សោ មេ ឧប្បជ្ជិ នោ មុញ្ចិ កោធោ ទុម្មេធគោចរោ។**

កាលសេចក្តីក្រោធកើតឡើងហើយ បុគ្គលរមែងមិនដឹងនូវប្រយោជន៍របស់ខ្លួន សេចក្តីក្រោធនោះ កើតឡើងដល់អាត្មាភាពហើយ ចេញមកមិនបានឡើយ សេចក្តីក្រោធជាទីគោចររបស់បុគ្គលល្ងង់ខ្លៅ ។

**យេនាភិភូតោ កុសលំ ជហាតិ**
**បរក្ករេ វិបុលញ្ចាបិ អត្ថំ**
**ស ភីមសេនោ ពលវា បមទ្ទិ**
**កោធោ មហារាជ ន មេ អមុច្ចថ ។**



បពិត្រមហារាជ បុគ្គលត្រូវសេចក្តីក្រោធណាគ្របសង្កត់ហើយ រមែងលះបង់ចោលនូវកុសលផង ធ្វើប្រយោជន៍ដ៏ធំទូលាយឱ្យសាបសូន្យផង បុគ្គលអ្នកក្រោធនោះ ត្រូវសេនាគឺកិលេសមួយកងពលធំ ដែលគួរឱ្យខ្លាចមាននូវកម្លាំង គ្របសង្កត់ញាំញី ឱ្យលុះក្នុងអំណាចបាន ប៉ុន្តែសេចក្តីក្រោធនោះ មិនអាចចេញពីអាត្មាភាពបានឡើយ ។

**កដ្ឋស្មឹ មត្ថមានស្មឹ បាវកោ នាម ជាយតិ**
**តមេវ កដ្ឋំ ទហតិ យស្មា សោ ជាយតេ គិនិ។**

ធម្មតាភ្លើង រមែងកើតក្នុងឈើដែលពួត (គឺកូតគ្នាទាល់តែក្តៅ រហូតឆេះចេញជាភ្លើង) ភ្លើងនោះ កើតអំពីឈើណា ក៏ឆេះនូវឈើនោះវិញ ។

**ឯវំ មន្ទស្ស បោសស្ស ពាលស្ស អវិជានតោ**
**សារម្ភា ជាយតេ កោធោ សោបិ តេនេវ ឌយ្ហតិ។**

សេចក្តីក្រោធ រមែងកើតឡើងដល់បុគ្គលពាលជាមនុស្សល្ងង់ខ្លៅមិនដឹងសេចក្តីពិត ព្រោះការប្រជែង

យកឈ្នះរៀងខ្លួន ម្ល៉ោះហើយ គេក៏ត្រូវសេចក្តីក្រោធនោះឯង ដុតឆ្លូលឆាបឆេះ ។

**អគ្គីវ តិណកដ្ឋស្មឹ    កោធោ យស្ស បវឌ្ឍតិ**
**និហីយតិ តស្ស យសោ    កាឡបក្ខេវ ចន្ទិមា ។**

សេចក្តីក្រោធ រមែងចម្រើនឡើងដល់បុគ្គលណា ដូចភ្លើងដែលចម្រើនឡើងក្នុងគំនរស្មៅនិងឈើ ដូច្នោះឯង យសរបស់បុគ្គលនោះ រមែងសាបសូន្យ ដូចព្រះចន្ទខាងរនោច ។

**អនិន្ធោ ធូមកេតូវ    កោធោ យស្សូបសម្មតិ**
**អាបូរតិ តស្ស យសោ    សុក្កបក្ខេវ ចន្ទិមាតិ ។**

សេចក្តីក្រោធរបស់បុគ្គលណា ស្ងប់រំងាប់ ដូចភ្លើងដែលអស់ស្មៅអស់ឈើដូច្នោះ យសរបស់បុគ្គលនោះ រមែងបរិបូណ៌ ដូចព្រះចន្ទខាងខ្នើត ។

ទាំង ៨ គាថា មានអដ្ឋកថា ដូចតទៅ :

បណ្តាបទទាំងនោះ បទថា **ន បស្សតិ** គឺរមែងមិនឃើញ សូម្បីតែប្រយោជន៍ខ្លួនឯង ចាំបាច់ពោលទៅ



ថ្វីដល់ប្រយោជន៍អ្នកដទៃ ។

បទថា **សាធុ បស្សតិ** បានដល់ រមែងឃើញប្រយោជន៍ទាំងពីរ គឺប្រយោជន៍ខ្លួន និងប្រយោជន៍អ្នកដទៃ បានដោយប្រពៃ ។

បទថា**ទុម្មេធគោចរោ**(សេចក្តីក្រោធ) គឺជាកន្លែងធានារ៉ាប់រងនៃបុគ្គលដែលប្រាសចាកបញ្ញាទាំងឡាយ ។

បទថា **ទុក្ខមេសិនោ** គឺចង់បានទុក្ខមកដាក់ខ្លួន ។

បទថា **សទត្ថំ** បានដល់ប្រយោជន៍របស់ខ្លួន គឺសេចក្តីចម្រើន ទាំងដោយអត្ថ ទាំងដោយធម៌ ។

បទថា **បរត្ថេ** បានដល់ ធ្វើប្រយោជន៍ធំទូលាយឱ្យជារបស់អ្នកដទៃ អ្នកទាំងឡាយចូរនាំចេញទៅ អាត្មាមិនត្រូវការដោយអ្វីនេះទេ (ពោលគឺធ្វើប្រយោជន៍ដ៏ធំឱ្យវិនាសសាបសូន្យ) ។

បទថា **ស ភីមសេនោ** ដោយសេចក្តីថា គេប្រកបដោយសេនា គឺកិលេសមួយកងពលធំ ដែលនឹង

ញាំងភ័យឱ្យកើតឡើង ។

បទថា **បមទ្ធិ** គឺព្រោះអំណាចដែលខ្លួនមានសេនា គឺកិលេសច្រើន ទើបជាអ្នកអាចចាប់សត្វទាំងឡាយ មកគ្របសង្កត់ញាំញី ធ្វើឱ្យនៅក្នុងអំណាចរបស់ខ្លួនបាន(នេះសម្តែងអំពីអំណាចនៃសេចក្តីក្រោធ) ។

បទថា **ន មេ អមុច្ចថ** ( អដ្ឋកថាថា **ន មេ អមុញ្ចិត្ថ** ) ដោយសេចក្តីថា មិនបានរបូតចេញពីសម្នាក់នៃអាត្មាភាពឡើយ ។

បទថា **ភដ្ឋស្មឹ មត្ថមានស្មឹ** បានដល់ ឈើដែលគេយកមកកូតគ្នា ។

បទថា **យស្មា** ដោយសេចក្តីថា ភ្លើងកើតឡើងអំពីឈើណា ក៏ដុតឈើនោះឯង ។ ភ្លើងឈ្មោះថា **គិនិ**។

បទថា **ពាលស្ស អវិជានតោ** គឺបុគ្គលល្ងង់ខ្លៅមិនដឹងការពិត ។

បទថា **សារម្ភា ជាយតេ** ដោយសេចក្តីថា



សេចក្តីក្រោធ រមែងកើតឡើងដល់បុគ្គលដែលទាញទៅទាញមក ព្រោះប្រណាំងប្រជែងគ្នា ដោយមានការធ្វើឱ្យហួសហេតុជាលក្ខណៈ ដូចភ្លើងព្រៃដែលកើតឡើងពីការកូតគ្នានៃឈើ ដូច្នោះឯង ។

បទថា **សោបិ តេនេវ** ដោយសេចក្តីថា ដែលគេជាមនុស្សល្ងង់ខ្លៅ ដូច្នេះទើបគេនោះត្រូវសេចក្តីក្រោធដុតឱ្យឆេះក្តៅរោលរាល ដល់នូវសេចក្តីអន្តរាយ ដូចឈើដែលត្រូវភ្លើងឆេះកម្ទេច ដូច្នោះដែរ ។

បាទនៃគាថា ថា **អនិន្ធោ ធូមកេតូវ** (អដ្ឋកថាថា **ធូមកេតុវ** ) ប្រែថា ដូចភ្លើងដែលមិនមានអ្វីដាក់ឱ្យឆេះ ។

បទថា **តស្ស** ជាដើម ដោយសេចក្តីថា យសដែលបុគ្គលប្រកបដោយអធិវាសនក្ខន្តិនោះ បានហើយរមែងពេញបរិបូណ៌ ដូចព្រះចន្ទខាងខ្នើត ដូច្នោះឯង ។

ព្រះរាជាទ្រង់ព្រះសណ្តាប់នូវធម្មកថា របស់ព្រះ-

បរមពោធិសត្វហើយ ក៏ត្រេកអរ ទើបបង្គាប់ឱ្យអាមាត្យម្នាក់ទៅនាំនាងបរិព្វាជិកាមកវិញ ហើយទ្រង់ត្រាស់ថា បពិត្រលោកម្ចាស់ដ៏ចម្រើន ដោយលោកម្ចាស់មិនមានសេចក្តីក្រោធ សូមលោកទាំងពីរតាំងនៅក្នុងសេចក្តីសុខដែលកើតអំពីបព្វជ្ជា ក្នុងព្រះរាជឧទ្យាននេះចុះ ខ្ញុំព្រះអង្គនឹងជួយពិភ័ក្តិរក្សាប្រកបដោយធម៌ដល់លោកទាំងពីរ ។

ព្រះរាជាបានសូមខមាទោស នមស្ការព្រះតាបសហើយ ស្តេចក៏បានចេញទៅ ។

បព្វជិតទាំងពីរអង្គ បានគង់នៅក្នុងព្រះរាជឧទ្យាននោះឯង ។ ក្រោយមកនាងបរិព្វាជិកាក៏ដល់នូវមរណភាព ចំណែកព្រះបរមពោធិសត្វ កាលដែលនាងបរិព្វាជិកាដល់នូវមរណភាពហើយ ក៏ចូលទៅកាន់ដែនដីនៃព្រៃហិមពាន្ត ធ្វើអភិញ្ញានិងសមាបត្តិឱ្យកើត ចម្រើនព្រហ្មវិហារ ៤ ហើយទៅកាន់ព្រហ្មលោក ។

ព្រះបរមសាស្តា កាលដែលព្រះអង្គទ្រង់នាំយកព្រះធម៌ទេសនានេះមកសម្តែងហើយ ព្រះអង្គប្រកាសនូវ



សច្ចធម៌ វេលាចប់សច្ចធម៌ ភិក្ខុដែលច្រើនដោយសេចក្តីក្រោធនោះ ក៏បានសម្រេចនូវព្រះអនាគាមិផល ។ ព្រះទសពលទ្រង់ប្រជុំជាតកថា នាងបរិព្វាជិកាក្នុងគ្រានោះ បានមកជាមាតារបស់រាហុលក្នុងពេលនេះ ព្រះរាជាក្នុងគ្រានោះ បានមកជាអានន្ទក្នុងពេលនេះ ចំណែកព្រះតាបសបរិព្វាជក បានមកជា **តថាគត** ដូច្នេះឯង ។

**(ចប់ចុល្លពោធិជាតក)**

## អត្ថគួរជ្រាប

មានប្រាក់សែនកោដិ ឬច្រើនជាងប៉ុនណាក៏ដោយ ក៏មិនអាចទិញសេចក្តីល្អយកមកដាក់ខ្លួនបានឡើយ មានតែការស្តាប់ពាក្យជាសុភាសិត ហើយធ្វើទុកក្នុងចិត្តឱ្យបានត្រឹមត្រូវប៉ុណ្ណោះ ទើបសិរីសួស្តីគឺសេចក្តីល្អចម្រើនឡើងក្នុងខ្លួន ដូចព្រះរាជាក្នុងរឿងនេះឯង ។

## ២~ លោមសកស្សបជាតក

( បិដកលេខ ៥៩ , ទំព័រ ១៤៨-១៤៩ និងអដ្ឋកថា )

ព្រះវិជិតមារ កាលដែលព្រះអង្គទ្រង់គង់ប្រថាប់នៅនាព្រះជេតពនមហាវិហារ ទ្រង់ប្រារព្ធនូវភិក្ខុមួយអង្គដែលលោកចង់សឹក ទើបត្រាស់នូវព្រះជាតកនេះ មានពាក្យថា **អស្ស ឥន្ទសមោ រាជ** ប៉ុណ្ណេះជាដើម ។

ដោយសង្ខេបក្នុងរឿងនេះ គឺព្រះបរមសាស្ដាត្រាស់សួរភិក្ខុអង្គនោះថា ម្នាលភិក្ខុ ឮថាអ្នកចង់សឹក ពិតមែនឬ ? កាលដែលភិក្ខុអង្គនោះក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ពិតមែន ដូច្នេះទើបព្រះបរមសាស្ដាត្រាស់ថា ម្នាលភិក្ខុ ខ្យល់ដែលបោកបក់ភ្នំសិនេរុឱ្យញាប់ញ័របាន ដូចម្ដេចទើបមិនបោកបក់ស្លឹកឈើចាស់ៗ ឱ្យញាប់ញ័របាននោះ ។ សូម្បីបុគ្គលដែលដល់ព្រមទៅដោយយសសព្វគ្រប់ ក៏នៅធ្លាក់ចូលក្នុងសេចក្ដីវិនាសនូវ



យសនោះ ។ ឈ្មោះថាកិលេសរមែងធ្វើសត្វដែលបរិសុទ្ធឱ្យសៅហ្មងបាន ចាំបាច់ពោលទៅថ្វី ដល់បុគ្គលដូចជាភិក្ខុឯងនេះ ។ រួចហើយ ព្រះដ៏មានព្រះភាគ ទ្រង់ក៏បាននាំយករឿងក្នុងអតីតមកសម្ដែងដូចតទៅ :

ក្នុងអតីតកាល ឱរសរបស់ព្រះបាទព្រហ្មទត្ត គ្រប់គ្រងព្រះនគរពារាណសី ព្រះនាមព្រហ្មទត្តកុមារ និងបុត្ររបស់បុរោហិត ឈ្មោះថា កស្សបៈ ជាសម្លាញ់នឹងគ្នារៀនសិល្បៈគ្រប់យ៉ាង ក្នុងត្រកូលអាចារ្យជាមួយគ្នា ។ ក្រោយមក កាលដែលព្រះរាជបិតាសោយព្រះទិវង្គត ព្រហ្មទត្តកុមារក៏បានគ្រងរាជសម្បត្តិ ។ ពេលនោះ កស្សបកុមារគិតថា សម្លាញ់របស់យើងជាព្រះរាជា ទ្រង់ប្រាកដជាព្រះរាជទានភាពជាធំឱ្យយើងដោយពិត តើប្រយោជន៍អ្វីដោយភាពជាធំសម្រាប់យើង យើងនឹងលាមាតាបិតានិងព្រះរាជា ចេញទៅបួសវិញ ។ កាលដែលកស្សបកុមារគិតដូច្នោះហើយ ទើបបានថ្វាយបង្គំលាព្រះរាជានិងមាតាបិតា ទៅកាន់ដែនដីនៃព្រៃហិមពាន្ត

បួសជាតាបស ក្នុងថ្ងៃទី ៧ ក៏បាននូវអភិញ្ញានិងសមាបត្តិ ចិញ្ចឹមជីវិតដោយផ្លែឈើ ។ មនុស្សទាំងឡាយ នាំគ្នាហៅព្រះតាបសថា លោមសកស្សបៈ ។ ព្រះតាបស មានឥន្ទ្រិយស្ងប់រំងាប់ដ៏ក្រៃលែង មានតបៈខ្លាំងក្លា ធ្វើឱ្យភពរបស់សក្កទេវរាជញាប់ញ័រ ដោយតេជះនិងតបៈរបស់ព្រះតាបសនោះឯង ។ លំដាប់នោះ សក្កទេវរាជ ទ្រង់ពិចារណាមើល ឃើញហេតុដូច្នោះហើយ ទ្រង់ព្រះតម្រិះថា ព្រះតាបសនេះ មានតេជះខ្ពង់ខ្ពស់ណាស់ នឹងធ្វើឱ្យយើងឃ្លាតចាកអំពីភាពជាព្រះឥន្ទបាន យើងនឹងរួមដៃជាមួយស្តេចក្រុងពារាណសី ទម្លាយតបៈរបស់ព្រះតាបសនោះ ។

គ្រានោះ សក្កទេវរាជ បានចូលទៅកាន់បន្ទប់សិរីសេយ្យាសន៍របស់ព្រះបាទក្រុងពារាណសី ក្នុងវេលាពាក់កណ្តាលនៃរាត្រី សម្តែងអានុភាពទ្រង់ជាព្រះឥន្ទបណ្តាលឱ្យបន្ទប់ភ្លឺស្វាង ដោយរស្មីនៃព្រះសរីរៈ ទ្រង់អណ្តែតឰដ៏អាកាសក្នុងសម្នាក់នៃព្រះរាជា ហើយត្រាស់



ហៅព្រះរាជាថា :

**សក្ក** : មហារាជ ចូរក្រោកឡើង ។

**រាជា** : អ្នកជាអ្នកណា ?

**សក្ក** : យើងគឺសក្កទេវរាជ ។

**រាជា** : ព្រះអង្គយាងមកដើម្បីអ្វី ?

**សក្ក** : មហារាជ ព្រះអង្គត្រូវការភាពជាឯករាជក្នុងជម្ពូទ្វីបទាំងអស់ ឬមិនត្រូវការទេ ?

**រាជា** : រឿងអ្វីដែលថាមិនត្រូវការ ។

**សក្ក** : បើដូច្នោះ ចូរព្រះអង្គនាំលោមសកស្សបតាបសឱ្យមកបូជាបសុឃាតយញ្ញ ព្រះអង្គនឹងស្មើដោយសក្កទេវរាជ មិនចាស់ហើយមិនស្លាប់ គ្រប់គ្រងរាជសម្បត្តិក្នុងជម្ពូទ្វីប ។

ព្រះឥន្ទបានពោលគាថាទី ១ ថា :

**អស្ស ឥន្ទសមោ រាជ អច្ចន្តំ អជរាមរោ**
**សចេ ត្វំ យញ្ញំ យជេយ្យ ឥសឹ លោមសកស្សបំ ។**

បពិត្រព្រះរាជា បើព្រះអង្គញុំាងឥសី ឈ្មោះលោមសកស្សបៈ ឱ្យមកបូជាយញ្ញបាន ព្រះអង្គនឹងបានទៅជាបុគ្គលមិនចាស់ មិនស្លាប់ ស្មើនឹងព្រះឥន្ទដោយពិត ។

បណ្តាបទទាំងនោះ បទថា **អស្ស** ប្រែថា នឹងបានជា ។

បទថា **យជេយ្យ** ដោយសេចក្តីថា បើព្រះអង្គនាំឥសីលោមសកស្សបៈពីទីនៅក្នុងព្រៃមកបូជាយញ្ញបាន។

លំដាប់នោះ ព្រះរាជាទ្រង់ព្រះសណ្តាប់ ព្រះតម្រាស់របស់សក្កទេវរាជហើយ ព្រះអង្គក៏ទទួលថា ល្អហើយ ។ គ្រានោះ សក្កទេវរាជត្រាស់តឿនថា បើដូច្នោះ សូមព្រះអង្គកុំគប្បីបង្អែបង្អង់ឡើយ ហើយក៏បាត់អំពីទីនោះទៅ ។ ថ្ងៃស្អែកឡើង ព្រះរាជាត្រាស់បង្គាប់ឱ្យហៅអាមាត្យឈ្មោះសេយ្យៈ មកត្រាស់ថា នែអាមាត្យ អ្នកចូរទៅកាន់សម្នាក់លោមសកស្សបៈ ដែលជាសម្លាញ់របស់យើង ចូរនិយាយតាមពាក្យរបស់យើងយ៉ាងនេះថា បពិត្រ



ព្រះតាបស ព្រះរាជាសូមឱ្យលោកម្ចាស់បូជាបសុឃាតយញ្ញ ព្រះរាជានឹងបានជាឯករាជលើជម្ពូទ្វីប ឯចំណែកលោកម្ចាស់ត្រូវការប្រទេសប៉ុនណា ព្រះរាជានឹងព្រះរាជទានប្រទេសប៉ុណ្ណោះដល់លោកម្ចាស់ ។ អាមាត្យសេយ្យៈ បានស្តាប់ដូច្នោះហើយ ក៏ក្រាបទូលព្រះរាជាថា ល្អហើយ ព្រះករុណាថ្លៃវិសេស ។ អាមាត្យសេយ្យៈ បានវាយស្គរប្រកាសក្នុងព្រះនគរ ដើម្បីបានដឹងទីនៅនៃព្រះតាបស កាលដែលអ្នកដើរព្រៃម្នាក់ប្រាប់ថា ខ្ញុំបាទដឹង ក៏បានឱ្យអ្នកដើរព្រៃនោះជាអ្នកនាំផ្លូវទៅព្រមដោយបរិវារយ៉ាងច្រើន ។ ទៅដល់ហើយបាននាំគ្នាថ្វាយបង្គំព្រះតាបស រួចក៏អង្គុយក្នុងទីដ៏សមគួរ ទើបអាមាត្យសេយ្យៈរៀបរាប់ពីដំណើរមក និងប្រកាសរាជសាសន៍ឱ្យព្រះតាបសបានជ្រាប ។ ព្រះតាបសស្តាប់ពាក្យរបស់អាមាត្យសេយ្យៈហើយទើបពោលថា ម្នាលសេយ្យៈ អ្នកនិយាយអ្វីហ្នឹង ។ កាលដែលព្រះតាបសពោលពាក្យបដិសេធ បានពោល ៤ គាថាដូច្នេះ ៖

**សសមុទ្ទបរិយាយំ មហឹ សាគរកុណ្ឌលំ**
**ន ឥច្ឆេ សហ និន្ទាយ ឯវំ សេយ្ហ វិជានហិ ។**

អាត្មាមិនប្រាថ្នានូវផែនដី ដែលមានសមុទ្រព័ទ្ធជុំវិញ ដូចជាកុណ្ឌលក្នុងសាគរ ព្រមដោយពាក្យតិះដៀលទេ ម្នាលសេយ្ហៈ អ្នកចូរដឹងយ៉ាងនេះចុះ ។

**ធិរត្ថុ តំ យសលាភំ ធនលាភញ្ច ព្រាហ្មណ**
**យា វុត្តិ វិនិបាតេន អធម្មចរណេន វា ។**

ម្នាលព្រាហ្មណ៍ការប្រព្រឹត្តចិញ្ចឹមជីវិតណា ដោយកិរិយាបំផ្លាញជីវិតគេ ឬដោយការប្រព្រឹត្តមិនត្រូវតាមធម៌ មុខគួរឱ្យតិះដៀលនូវការបានយស និងការបាននូវទ្រព្យដោយការប្រព្រឹត្តនោះ ។

**អបិ ចេ បត្តមាទាយ អនាគារោ បរិព្វជេ**
**សាយេវ ជីវិកា សេយ្យោ យា ចាធម្មេន ឯសនា ។**

បុគ្គលបួសនិមន្តដើរបិណ្ឌបាត ការចិញ្ចឹមជីវិតនោះ ប្រសើរជាងការស្វែងរកខុសធម៌ ។



**អបិ ចេ បត្តមាទាយ អនាគារោ បរិព្វជេ**
**អញ្ញំ អហឹសយំ លោកេ អបិ រជ្ជេន តំ វរំ ។**

បុគ្គលបួសនិមន្តដើរបិណ្ឌបាត ដោយមិនបៀតបៀនជនដទៃ ដំណើរនោះ ប្រសើរជាងរាជសម្បត្តិក្នុងលោកទៅទៀត ។

បណ្តាបទទាំងនោះ បទថា **សសមុទ្ទបរិយាយំ** គឺដែលមានសមុទ្រព័ទ្ធជុំវិញ ។

បទថា **សាគរកុណ្ឌលំ** គឺដែលប្រកបដោយសាគរព័ទ្ធជុំវិញទិ្វបទាំង ៤ ដូចកុណ្ឌលដែលគេពាក់នឹងត្រចៀកដូច្នោះឯង ។

បទថា **សហ និន្ទាយ** ដោយសេចក្តីគឺលោមសកស្សបតាបសពោលថា អាត្មាមិនប្រាថ្នាសូម្បីមហាប្រឹថពី ដែលមានចក្កវាឡជាទីបំផុត ព្រមដោយពាក្យនិន្ទាថា លោមសកស្សបតាបសនេះ បានធ្វើបសុឃាតកម្មហើយ ។

ដោយបទថា **យា វុត្តិ វិនិបាតេន** លោមស-កស្សបតាបស សម្តែងថា យើងតិះដៀលការប្រព្រឹត្តទៅនៃជីវិតបែបនោះ គឺតិះដៀលការប្រព្រឹត្តនោះ ព្រោះជាកម្មដែលឱ្យធ្លាក់ទៅក្នុងនរក ។

បទថា **សាយេវ ជីវិកា** ដោយសេចក្តីថា ការរស់នៅដោយវិធីបីបាត្រ ដើរចូលទៅកាន់ផ្ទះនៃអ្នកដទៃស្វែងរកអាហាររបស់បព្វជិតនោះឯង ល្អជាងការបានយស បានទ្រព្យរាប់រយពាន់ដងទៅទៀត ។

បទថា **អបិ រជ្ជេន តំ វរំ** ដោយសេចក្តីថា ការវៀរចាកអំពើអាក្រក់របស់បព្វជិត ដែលជាបុគ្គលមិនបៀតបៀនអ្នកដទៃនោះ ប្រសើរជាងភាពជាព្រះរាជាក្នុងជម្ពូទ្វីបទាំងអស់ ។

អាមាត្យ ស្តាប់ពាក្យរបស់ព្រះតាបសនោះហើយបានត្រឡប់មកក្រាបទូលដល់ព្រះរាជា ព្រះរាជាទ្រង់ព្រះសណ្តាប់ដូច្នោះក៏ត្រាស់ថា បើលោកមិនមក យើងក៏មិន



អាចធ្វើអ្វីបាន ហើយទ្រង់ក៏ស្ងៀមទៅ ។ លំដាប់នោះសក្កទេវរាជ ស្តេចយាងមកពេលអធ្រាត្រម្តងទៀត ទ្រង់ប្រថាប់នៅក្នុងអាកាស ត្រាស់ថា បពិត្រមហារាជ ហេតុអ្វី ទើបព្រះអង្គមិនត្រាស់បង្គាប់ឱ្យលោមសកស្សបតាបសមកបូជាយញ្ញ ? ព្រះរាជាត្រាស់ថា ខ្ញុំព្រះអង្គបានបញ្ជូនអាមាត្យទៅប្រាប់ហើយ តែលោកមិនមក ។ សក្កទេវរាជត្រាស់ថា បពិត្រមហារាជ បើដូច្នោះ ចូរព្រះអង្គតាក់តែងព្រះនាងចន្ទវតី ដែលជាព្រះរាជធីតារបស់ព្រះអង្គ ហើយប្រគល់ឱ្យអាមាត្យសេយ្យៈ នាំទៅប្រាប់ថា « បើលោកម្ចាស់ទៅបូជាយញ្ញ ព្រះរាជានឹងព្រះរាជទាននូវព្រះរាជ-ធីតានេះ ដល់លោកម្ចាស់ » ដូច្នេះព្រះតាបសនោះនឹងមានចិត្តប្រតិព័ទ្ធដល់ព្រះរាជធីតា ប្រាកដជាមកមិនខានឡើយ ។ ព្រះរាជាទ្រង់ព្រះសណ្តាប់ហើយ ទ្រង់ក៏ទទួលថា ល្អមែន ។

ថ្ងៃស្អែកឡើង ព្រះរាជាទ្រង់ប្រគល់ព្រះរាជធីតានៃព្រះអង្គឱ្យអាមាត្យសេយ្យៈនាំយកទៅ ។ អាមាត្យសេយ្យៈ

នាំព្រះរាជធីតាទៅក្នុងទីនោះ បានថ្វាយបង្គំព្រះតាបស ហើយសម្តែងនូវព្រះរាជធីតា ដែលមានរូបស្អាតដូចជាទេពអប្សរដល់ព្រះតាបស ។ លំដាប់នោះ ព្រះតាបសបានបែកធ្លាយនូវឥន្ទ្រិយ ព្រមជាមួយគ្នានឹងការសម្លឹងមើលព្រះរាជធីតានោះឯង ។ ព្រះតាបសមានចិត្តប្រតិព័ទ្ធស្រឡាញ់ព្រះរាជធីតា ហើយក៏សូន្យចាកឈាន ។ អាមាត្យសេយ្ហៈ ដឹងថាព្រះតាបសមានចិត្តប្រតិព័ទ្ធជំពាក់ចំពោះព្រះរាជធីតាដូច្នេះហើយ ទើបពោលថា បពិត្រលោកម្ចាស់ បើលោកម្ចាស់និមន្តទៅបូជាយញ្ញ ព្រះរាជានឹងព្រះរាជទាននូវព្រះរាជធីតានេះ ឱ្យជាបាទបរិចារិកាសម្រាប់លោកម្ចាស់ ។ ព្រះតាបស កំពុងតែញាប់ញ័រទៅដោយអំណាចកិលេស ទើបសួរបញ្ជាក់ថា បានឮថាព្រះរាជានឹងព្រះរាជទាននូវព្រះរាជធីតានេះ ដល់អាត្មាមែនឬ ? អាមាត្យក៏តបថា ត្រូវហើយ ព្រះរាជានឹងព្រះរាជទានដល់លោកម្ចាស់ ដែលជាអ្នកបូជាយញ្ញ ។ ព្រះតាបសពោលថា ល្អណាស់ កាលបើយើងបានព្រះ-



រាជធីតានេះ យើងនឹងបូជាយញ្ញ ។ រួចហើយព្រះតាបសបានរៀបចំនូវជដាឱ្យមានសភាពស្រួលបួល នាំព្រះរាជ-ធីតាឡើងរថ ដែលប្រដាប់តាក់តែងល្អហើយ មកកាន់ព្រះនគរពារាណសី ។

ព្រះរាជា បានជ្រាបថា ព្រះតាបសមកហើយ ក៏ត្រាស់បង្គាប់ឱ្យតាំងពិធីឡើង នៅឯរណ្តៅបូជាយញ្ញសម្រាប់ព្រះតាបសនោះឯង ។ កាលដែលបានទតព្រះនេត្រឃើញព្រះតាបសមកដល់ ក៏ត្រាស់ថា លោកបូជាយញ្ញក្នុងថ្ងៃស្អែកនេះ យើងនឹងជាអ្នកស្មើដោយព្រះឥន្ទ្រ ពេលដែលបូជាយញ្ញចប់ស្រេចបាច់ហើយ យើងនឹងប្រគល់ធីតាដល់លោក ។ លោមសកស្សបតាបសបានទទួលថា ល្អហើយមហារាជ ។

លុះវេលាថ្ងៃប្រារព្ធពិធីមកដល់ ព្រះរាជាបាននាំព្រះតាបសទៅកាន់រណ្តៅបូជាយញ្ញ ព្រមជាមួយព្រះ-នាងចន្ទវតី ។ ក្នុងរណ្តៅនោះ មានសុទ្ធតែសត្វជើង ៤ ដូចជាដំរី សេះ គោជាដើម តាំងទុកតាមលំដាប់ ។ ព្រះ-

តាបសផ្ដើមនឹងសម្លាប់សត្វទាំងអស់នោះ ដើម្បីបូជាយញ្ញ ឯមហាជនដែលមកប្រជុំគ្នាក្នុងទីនោះឃើញដូច្នោះ ក៏ពោលថា នែ លោមសកស្សបៈ កម្មនេះមិនសមគួរដល់លោកទេ លោកធ្វើយ៉ាងនេះដើម្បីអ្វី ។ មហាជនមានការយំសោក ហើយនាំគ្នាពោលនូវគាថា ២ គាថា :

**ពលំ ចន្ទោ ពលំ សុរិយោ ពលំ សមណព្រាហ្មណា**
**ពលំ វេលា សមុទ្ទស្ស ពលាតិពលមិត្ថិយោ ។**

ព្រះចន្ទមានកម្លាំង ព្រះអាទិត្យមានកម្លាំង ពួកសមណព្រាហ្មណ៍មានកម្លាំង ច្រាំងសមុទ្រមានកម្លាំង ឯពួកស្ត្រី មានកម្លាំងដ៏ក្រៃលែងជាងកម្លាំងនោះៗ ទៅទៀត ។

**យថា ឧគ្គតបំ សន្តំ ឥសឹ លោមសកស្សបំ**
**បិតុ អត្ថាយ ចន្ទវតី វាជបេយ្យំ អយាជយិ ។**

ដូចជាព្រះរាជធីតា ឈ្មោះចន្ទវតី បានញ៉ាំងឥសីឈ្មោះលោមសកស្សបៈ ដែលមានតបៈដ៏ខ្ពង់ខ្ពស់ ឱ្យមកធ្វើយញ្ញ ឈ្មោះវាជបេយ្យៈ គឺបូជាដោយការសម្លាប់សត្វចិញ្ចឹម ដើម្បីប្រយោជន៍ដល់ព្រះបិតា ។

បណ្ដាបទទាំងនោះ បទថា **ពលំ ចន្ទោ ពលំ សុរិយោ** ដោយសេចក្ដីថា ក្នុងការកម្ចាត់នូវភាពងងឹតក្នុងលោក ឈ្មោះថាកម្លាំងដទៃរមែងមិនមាន ក្នុងការកម្ចាត់នូវភាពងងឹតដ៏ក្រៃលែងនេះ មានតែព្រះចន្ទ និងព្រះអាទិត្យប៉ុណ្ណោះ ទើបមានកម្លាំង ។

បទថា **សមណព្រាហ្មណា** ដោយសេចក្ដីថា ក្នុងការអត់ធន់ចំពោះកម្លាំងនៃឥដ្ឋារម្មណ៍ គឺអារម្មណ៍ជាទីពេញចិត្ត និងអនិដ្ឋារម្មណ៍ គឺអារម្មណ៍មិនជាទីពេញចិត្ត សមណព្រាហ្មណ៍ដែលប្រកបដោយកម្លាំងខន្តី និងកម្លាំងញាណ ឈ្មោះថា មានកម្លាំង ។

បទថា **ពលំ វេលា សមុទ្ទស្ស** ដោយសេចក្ដីថា ច្រាំងនៃមហាសមុទ្រ ឈ្មោះថាមានកម្លាំង ព្រោះអាចទប់ទឹកមហាសមុទ្របាន ។

បទថា **ពលាតិពលមិត្តិយោ** ដោយសេចក្តីថា ស្រ្តីទាំងឡាយ ឈ្មោះថាមានកម្លាំងដ៏ក្រៃលែងជាងកម្លាំងទាំងអស់ ព្រោះអាចនឹងនាំបុរសដែលមានការចេះដឹងល្អ តែមានតម្រេក ឱ្យមកនៅក្នុងអំណាចរបស់ខ្លួន ហើយឱ្យវិនាសបាន ។ អធិប្បាយថា មានតែកម្លាំងនៃស្រ្តីប៉ុណ្ណោះ ដែលខ្លាំងជាងកម្លាំងទាំងអស់ ។

ស័ព្ទថា **យថា** ដូចគ្នានឹង **យស្មា** ប្រែថា ព្រោះហេតុណា ។

បទថា **ចិត្ត អត្ថាយ** គឺដើម្បីប្រយោជន៍នៃសេចក្តីចម្រើនដល់ព្រះរាជបិតា ។

សេចក្តីនៃព្រះគាថា គឺមហាជនចង់បញ្ជាក់ថា ព្រោះព្រះនាងចន្ទវតីនេះ បានធ្វើលោមសកស្សបៈជាអ្នកមានតបៈខ្លាំងក្លា ជាមហាឥសី ព្រោះជាអ្នកស្វែងរកគុណទាំងឡាយ មានសីលគុណជាដើម ឱ្យទៅជាអ្នកមិនមានសីល ឱ្យមកបូជាវាជបេយ្យៈ គឺយញ្ញ ដើម្បីប្រយោជន៍



ដល់ព្រះរាជបិតាបាន ដូច្នោះ ចំណុចនេះ បណ្ឌិតគប្បីជ្រាបថា ស្រ្តីមានកម្លាំងក្រៃលែងជាងកម្លាំងទាំងឡាយ។

ខណៈនោះ លោមសកស្សបតាបស លើកព្រះខាន់កែវឡើង ដោយគិតថា នឹងកាត់កដំរីមង្គលដើម្បីបូជាយញ្ញ ដំរីឃើញដូច្នោះ ក៏តក់ស្លុតខ្លាចចំពោះមរណ-ភ័យ ទើបស្រែកដោយសំឡេងខ្លាំងៗ សូម្បីពួកសត្វក្រៅអំពីនេះ បានឮសម្រែករបស់ដំរីមង្គលនោះ ក៏នាំគ្នាតក់-ស្លុតខ្លាចមរណភ័យ ហើយបានស្រែកលាន់ទ្រហឹង ឯចំណែកមហាជនក៏ស្រែកព្រមគ្នាផងដែរ ។ ព្រះតាបសបានឮសម្រែកកងរំពងដូច្នេះ ក៏ស្លុតចិត្ត សម្លឹងមើលជដាជាដើមរបស់ខ្លួន លំដាប់នោះ ជដា ពុកមាត់ពុកចង្ការោមក្លៀក រោមទ្រូងបានប្រាកដដល់ព្រះតាបសនោះ ។ ព្រះតាបស មានការក្តៅក្រហាយចិត្ត គិតថា យើងបានធ្វើកម្មលាមក មិនសមគួរឡើយ ។ កាលដែលនឹងប្រកាសសេចក្តីស្លុតចិត្តរបស់ខ្លួន ព្រះតាបសបានពោលព្រះគាថាទី ៨ ថា :

**តំ លោភបកតំ កម្មំ      កដុកំ កាមហេតុកំ**
**តស្ស មូលំ គវេសិស្សំ      ឆេជ្ជំ រាគំ សពន្ធនំ ។**

អំពើដែលធ្វើដោយសេចក្ដីលោភនោះ ជាអំពើក្ដៅក្រហាយ មានកាមជាហេតុ អាត្មានឹងស្វែងរកឫសនៃអំពើនោះ នឹងកាត់នូវរាគៈ ព្រមទាំងចំណង ។

គប្បីជ្រាបសេចក្ដីនៃព្រះគាថានោះថា បពិត្រព្រះរាជាដ៏ជាធំ អំពើណាដែលអាត្មាធ្វើដោយលោភៈចំពោះនាងចន្ទវតី អំពើនោះ មានកាមជាហេតុ ជាអំពើលាមក ក្ដៅក្រហាយ មានវិបាកខ្លាំងក្លា អាត្មាភាពនឹងស្វែងរកឫសគល់ ពោលគឺអយោនិសោមនសិការនៃអំពើនោះ សមគួរហើយអាត្មាភាពនឹងដកដាវគឺបញ្ញា ចេញមកកាត់នូវរាគៈ ព្រមទាំងចំណងគឺសុភនិមិត្ត ។

លំដាប់នោះ ព្រះរាជាបានត្រាស់ទៅរកព្រះ-តាបសថា នែសម្លាញ់ កុំខ្លាចអ្វីឡើយ យើងនឹងឱ្យនាងចន្ទវតីនិងកែវកង ៧ ប្រការដល់អ្នកក្នុងកាលឥឡូវនេះ អ្នកចូរបបួលជាយញ្ញចុះ ។ ព្រះតាបសបានស្ដាប់ហើយ ទើប



ពោលតបថា បពិត្រមហារាជ អាត្មាមិនត្រូវការដោយកិលេសនេះឡើយ ។ ព្រះតាបស បានពោលព្រះគាថាទី ៩ ជាព្រះគាថាចុងក្រោយថា :

**ធិរត្ថុ កាមេ សុពហូបិ លោកេ**
**តបោវ សេយ្យោ កាមគុណេហិ រាជ**
**តបោ ករិស្សាមិ បហាយ កាមេ**
**តវេវ រដ្ឋំ ចន្ទវតី ច ហោតូតិ ។**

មុខគួរឱ្យតិះដៀលនូវកាមទាំងឡាយ ដ៏ច្រើនក្រៃ-ពេកក្នុងលោក បពិត្រព្រះរាជា ការព្យាយាមប្រព្រឹត្តតបៈដុតបំផ្លាញនូវកិលេស ប្រសើរបំផុតជាងកាមគុណទាំង-ឡាយ អាត្មានឹងលះបង់នូវកាមទាំងឡាយ ហើយប្រព្រឹត្តតបៈដុតបំផ្លាញកិលេស ចំណែកដែនដីនិងព្រះនាងចន្ទវតីចូរនៅជា របស់ព្រះអង្គចុះ ។

បណ្ដាបទទាំងនោះ បទថា **សុពហូបិ** គឺសូម្បីដ៏ច្រើនក្រៃលែង ។

បទថា **តធោ ភរិស្សាមិ** គឺនឹងបំពេញសេចក្តីសង្រួមក្នុងសីលតែប៉ុណ្ណោះ ។

ព្រះតាបស កាលដែលទូលព្រះរាជាដូច្នេះហើយ បានប្រមូលកសិណបរិកម្ម ធ្វើគុណវិសេសដែលបាត់បង់ទៅ ឱ្យកើតឡើងវិញ អង្គុយលើបល្ល័ង្កឰដ៏អាកាស សម្តែងព្រះធម៌ថ្វាយព្រះរាជាថា ព្រះអង្គចូរកុំប្រមាទ ហើយទម្លាយរណ្តៅបូជាយញ្ញ ឱ្យអភយទានដល់មហាជននិងពពួកសត្វ ។ កាលព្រះរាជានៅតែអង្វរករ ព្រះតាបសបានហោះទៅកាន់កន្លែងរបស់ខ្លួន ចម្រើនព្រហ្មវិហារធម៌ រហូតអស់ជីវិត ទៅកាន់ព្រហ្មលោក ។

ព្រះបរមសាស្តា កាលដែលព្រះអង្គបាននាំយកព្រះធម៌ទេសនានេះមកសម្តែងដូច្នេះហើយ ទ្រង់ប្រកាសនូវសច្ចធម៌ ។ វេលាចប់នូវសច្ចធម៌ ភិក្ខុដែលអផ្សុកចង់លាសិក្ខានោះ បានតាំងនៅក្នុងព្រះអរហត្តផល ។ ព្រះទសពលទ្រង់ប្រជុំជាតកថា អាមាត្យសេយ្យៈក្នុងគ្រានោះ



បានមកជាសារីបុត្តក្នុងគ្រានេះ ចំណែកលោមសកស្សបតាបស បានមកជា **តថាគត** ។

**(ចប់លោមសកស្សបជាតក)**

## អត្ថគួរជ្រាប

យើងមិនសេពគប់និងជនពាល តែយើងបានសេពគប់ហើយនូវពាលធម៌ក្នុងខ្លួន ។ ពាលធម៌គឺកិលេសក្នុងខ្លួន បាននាំយើងឱ្យធ្វើនូវកិច្ចការឆ្គាំឆ្គងយ៉ាងច្រើន ទាំងយើងក៏បានធ្វើតាមហើយដែរ ។

ជាអវិជ្ជាដ៏ក្រៃលែង ដែលសត្វលោកយើងបានទទួលហើយនូវបញ្ចក្ខន្ធ យកមកប្រកាន់ធ្វើជាខ្លួនឯងម្ល៉ោះហើយ ត្រូវរវល់ចិញ្ចឹម មើលថៃ រក្សាការពារ និងរវល់ស្វែងរកអ្វីៗសព្វគ្រប់ ដើម្បីផ្គាប់ផ្គុន ទាំងដែលបញ្ចក្ខន្ធនេះ ជាអ្នកសម្លាប់យើងទៀតផង ។

# ៣. វេឡុកជាតក

(បិដកលេខ ៥៨ , ទំព័រ ២០ និងអដ្ឋកថា)

ព្រះបរមសាស្ដា កាលដែលព្រះអង្គទ្រង់គង់ប្រថាប់នៅនាព្រះជេតពនមហាវិហារ ទ្រង់បានប្រារព្ធភិក្ខុលំបាកប្រដៅមួយអង្គ ត្រាស់ព្រះធម៌ទេសនានេះ មានពាក្យថា **យោ អត្ថកាមស្ស** ជាដើម ។

មានរឿងសង្ខេបថា ព្រះដ៏មានព្រះភាគ ត្រាស់សួរភិក្ខុនោះថា ម្នាលភិក្ខុ ពិតឬ ដែលថាអ្នកជាបុគ្គលមិនងាយប្រដៅ ? កាលភិក្ខុអង្គនោះក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ពិតមែន ដូច្នេះហើយ ទ្រង់ក៏ត្រាស់ថា ម្នាលភិក្ខុ មិនមែនត្រឹមតែក្នុងជាតិនេះទេ សូម្បីជាតិមុនអ្នកក៏ជាបុគ្គលមិនងាយប្រដៅដូចគ្នាដែរ ។ ព្រោះភាពជាបុគ្គលដែលលំបាកប្រដៅនោះឯង ទើបមិនធ្វើតាមពាក្យទូន្មានរបស់បណ្ឌិតទាំងឡាយ ហើយត្រូវពស់ខាំ



ស្លាប់ ។ ដូច្នេះហើយ ទ្រង់នាំយករឿងក្នុងអតីតមកសម្ដែង ដូចតទៅ :

ក្នុងអតីតកាល គ្រាដែលព្រះបាទព្រហ្មទត្តសោយ-រាជសម្បត្តិក្នុងនគរពារាណសី ព្រះបរមពោធិសត្វកើតក្នុងត្រកូលដែលមានសម្បត្តិច្រើន ក្នុងដែនកាសី ។ កាលដែលព្រះបរមពោធិសត្វដឹងក្ដីហើយ ក៏សម្លឹងឃើញទោសក្នុងកាមគុណ និងអានិសង្សក្នុងការចេញទៅបួស ទើបលះកាមទាំងឡាយ ហើយចូលទៅកាន់ព្រៃហិមពាន្ត បួសជាតាបស បំពេញកសិណបរិកម្ម ធ្វើអភិញ្ញា ៥ និងសមាបត្តិ ៨ ឱ្យកើតហើយ ឋិតនៅក្នុងសេចក្ដីសុខ ដែលកើតអំពីឈាន លុះកាលក្រោយមក ក៏បានតាបសជាបរិវារយ៉ាងច្រើន រហូតដល់ ៥០០ អង្គ ។ កាលនោះមានកូនអាសិរពិសមួយ វារទៅតាមធម្មតារបស់ខ្លួន រហូតដល់អាស្រមបទរបស់តាបសមួយអង្គ ។ តាបសឃើញហើយកើតសេចក្ដីស្រឡាញ់ ដូចឪពុកស្រឡាញ់កូន ទើបចាប់យកមកចិញ្ចឹមទុកក្នុងបំពង់ឫស្សី ។ ព្រោះហេតុកូន

ពស់នោះនៅក្នុងបំពង់ឫស្សី តាបសទាំងឡាយទើបឱ្យឈ្មោះថាវេឡុកៈ និងព្រោះហេតុដែលតាបសនោះចិញ្ចឹមមើលថែដោយសេចក្តីស្រឡាញ់ដូចជាបុត្ររបស់ខ្លួន តា-បសទាំងឡាយនោះ ក៏ហៅតាបសដែលចិញ្ចឹមកូនពស់នោះឯងថា វេឡុកបិតា ។

ព្រះបរមពោធិសត្វ បានឮដំណឹងថា តាបសមួយអង្គចិញ្ចឹមអាសិរពិស ទើបហៅមកសួរថា បានឮថាលោកចិញ្ចឹមអាសិរពិសពិតមែនឬ ? កាលដែលតាបសអង្គនោះ តបថា ពិតមែន ព្រះបរមពោធិសត្វ ក៏ពោលដាស់តឿនថា ដែលឈ្មោះថាអាសិរពិស ទុកចិត្តមិនបានឡើយ លោកកុំចិញ្ចឹមវាទុកតទៅទៀត ។ តាបសតបថា បពិត្រលោកអាចារ្យ វាដូចជាកូនរបស់ខ្ញុំព្រះករុណាទៅហើយ ខ្ញុំព្រះករុណា មិនអាចព្រាត់ពីវាបានទេ ។ ព្រះ-បរមពោធិសត្វដាស់តឿន ជាច្រើនលើក ដោយរំលឹកថា លោកនឹងដល់នូវសេចក្តីស្លាប់ បើលោកចេះតែជិតដិតនឹងវា ។ តាបសនោះ មិនជឿពាក្យទូន្មានរបស់ព្រះបរម-



ពោធិសត្វឡើយ ហើយក៏មិនបានលែងចោលនូវអាសិរ-ពិសនោះដែរ ។

ប៉ុន្មានថ្ងៃក្រោយមក តាបសទាំងអស់នាំគ្នាទៅរកផលាផល កាលដែលទៅដល់ហើយ ក៏ឃើញថា ផលា-ផលរកបានដោយងាយ ហើយក៏សម្រាកនៅក្នុងទីនោះ ២-៣ ថ្ងៃ ។ សូម្បីតាបសវេឡុកបិតា ក៏បានទៅរួមគ្នាជាមួយនឹងពួកតាបសទាំងនោះដែរ ដោយឱ្យអាសិរពិសដេកក្នុងបំពង់ឫស្សី បិទមាត់បំពង់ស្រួលបួលហើយទើបទៅ ។ កន្លងទៅ ២-៣ ថ្ងៃ ទើបត្រឡប់មកជាមួយគ្នាដោយគិតថា យើងនឹងឱ្យអាហារដល់វេឡុកៈ បើកមាត់បំពង់ឫស្សីហើយពោលថា មកកូនសម្លាញ់ កូនប្រាកដជាឃ្លានហើយ ។ គ្រាន់តែតាបសវេឡុកបិតា លូកដៃចូលទៅ អាសិរពិសវាក្រោធ ព្រោះអត់អាហារ ២-៣ ថ្ងៃ ហើយខាំដៃដែលលូកចូលទៅនោះ ធ្វើឱ្យតាបសអស់ជីវិតត្រង់ទីនោះឯង ហើយពស់នោះក៏វារចូលព្រៃបាត់ទៅ ។ តាបសទាំងឡាយ ឃើញដូច្នោះ ក៏ប្រគេនដំណឹង

ដល់ព្រះបរមពោធិសត្វ ព្រះបរមពោធិសត្វ ក៏បានបង្គាប់ឱ្យធ្វើកិច្ចចំពោះសរីរៈនៃតាបសវេឡុកបិតានោះ ហើយគង់នៅកណ្ដាលនៃពួកតាបស ពោលគាថាដូច្នេះថា :

**យោ អត្ថកាមស្ស ហិតានុកម្បិនោ**

**ឱវជ្ជមានោ ន ករោតិ សាសនំ**

**ឯវំ សោ និហតោ សេតិ វេឡុកស្ស យថា បិតាតិ។**

បុគ្គលណា កាលដែលលោកអ្នកប្រាថ្នាសេចក្ដីចម្រើន អនុគ្រោះដោយប្រយោជន៍ ទូន្មាន ហើយមិនធ្វើតាមពាក្យប្រៀនប្រដៅ បុគ្គលនោះ រមែងដេកស្លាប់ ដូចតាបសជាបិតានៃពស់ឈ្មោះវេឡុកៈ ដូច្នោះឯង ។

បណ្ដាបទទាំងនោះ បទថា **ឯវំ សោ និហតោ សេតិ** ដោយសេចក្ដីថា ក៏បុគ្គលណា មិនជឿពាក្យទូន្មានប្រៀនប្រដៅរបស់ឥសីទាំងឡាយ បុគ្គលនោះ រមែងដល់នូវសេចក្ដីវិនាសដ៏ក្រៃលែង គឺត្រូវវិបត្តិកម្ចាត់បង់នូវជីវិត ដេកស្លាប់ដូចតាបសនេះ ដែលត្រូវវិបត្តិកម្ចាត់បង់ឱ្យដល់នូវភាពហើមស្អុយ ដេកស្លាប់ព្រោះអាសិរពិសដូច្នោះ។



ព្រះបរមពោធិសត្វ ទូន្មានពួកតាបសយ៉ាងនេះ ហើយ អប់រំព្រហ្មវិហារ ៤ ឱ្យចម្រើន លុះដល់អស់ជីវិត ក៏ទៅបដិសន្ធិក្នុងព្រហ្មលោក ។

ព្រះបរមសាស្ដាទ្រង់ត្រាស់ថា ម្នាលភិក្ខុ មិនមែនតែក្នុងជាតិនេះទេ ដែលអ្នកជាបុគ្គលប្រដៅបានដោយលំបាក សូម្បីក្នុងជាតិមុន អ្នកក៏ជាបុគ្គលប្រដៅបានដោយលំបាកដែរ និងព្រោះភាពជាបុគ្គលដែលលំបាកប្រដៅនោះឯង ទើបដល់នូវភាពហើមស្អុយ ព្រោះមាត់អាសិរពិសជាហេតុ ។

កាលដែលព្រះបរមសាស្ដា នាំព្រះធម៌ទេសនានេះមកហើយ ទ្រង់បន្តអនុសន្ធិប្រជុំជាតកថា តាបសវេឡុក-បិតា ក្នុងកាលនោះ ជាភិក្ខុប្រដៅបានដោយលំបាកក្នុងពេលនេះ បរិស័ទគឺតាបសផ្សេងទៀត បានមកជាពុទ្ធបរិ-ស័ទ ឯសាស្ដានៃពួកតាបស គឺជា **តថាគត** នេះឯង។

**(ចប់វេឡុកជាតក)**

### អត្ថគួរជ្រាប

មហាភូតរូប ៤ ក្តី កាមគុណ ៥ ក្តី កិលេសផ្សេងៗក្តី បីដូចអាសិរពិស ។ មានសេចក្តីអធិប្បាយដូចតទៅ :

-មហាភូតរូប ៤ គឺធាតុដី ធាតុទឹក ធាតុភ្លើង និងធាតុខ្យល់ បានដល់រូបកាយនេះឯង ដែលយើងខំចិញ្ចឹមមើលថែ ព្រមទាំងស្រឡាញ់ ប៉ុន្តែវាសែនអកតញ្ញូ វាត្រឡប់មកខាំយើង ឱ្យយើងឈឺដល់នូវទុក្ខវេទនាហើយស្លាប់ ដូច្នេះត្រូវរត់ចេញពីវា ដោយវិបស្សនាញាណ ។

-កាមគុណ ៥ គឺរូប សំឡេង ក្លិន រស ផោដ្ឋព្វៈជាទីត្រេកត្រអាល វាខាំអ្នកដែលស្និទ្ធស្នាលនឹងវា ឱ្យសោកសៅដំបៅដើមទ្រូង និងយំស្រែកក្នុងឋាននរក ។

-កិលេសមានរាគៈ ទោសៈជាដើម គឺជាមេពិសដែលបានជ្រាបចូលដល់ភវង្គចិត្តឋិតនៅជាអនុស័យ ដែលធ្វើឱ្យមនុស្សលោកក្លាយជាអាសិរពិស ទាំងដែលមានរូបរាងជាមនុស្ស ។



## ៤. សេរិវពាណិជជាតក

(បិដកលេខ ៥៨ , ទំព័រ ២ និងអដ្ឋកថា )

ព្រះដ៏មានព្រះភាគ កាលដែលទ្រង់គង់ប្រថាប់នៅក្រុងសាវត្ថី ទ្រង់ប្រារព្ធភិក្ខុមួយអង្គដែលលះបង់សេចក្តីព្យាយាម ទើបត្រាស់នូវព្រះធម៌ទេសនានេះថា **ឥធ ចេ នំ វិរាធេសិ** ប៉ុណ្ណេះជាដើម ។

ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកបួសក្នុងសាសនា ដែលឱ្យបានសម្រេចនូវមគ្គផល មានសភាពបែបនេះ អ្នកបែរជាលះបង់នូវសេចក្តីព្យាយាមចោល អ្នកនឹងសោកសៅរហូតអស់កាលជាអង្វែង ដូចសេរិវពាណិជ បានវិនាសចាកថាសមាស ដែលមានតម្លៃមួយសែនកហាបណៈ ដូច្នោះឯង ។

ភិក្ខុទាំងឡាយ បានទូលអារាធនាព្រះដ៏មានព្រះ-ភាគ សូមព្រះអង្គទ្រង់សម្តែងរឿងនោះ ដើម្បីឱ្យបាន

ច្បាស់ប្រាកដដល់ពួកខ្ញុំព្រះអង្គ ។ ព្រះដ៏មានព្រះភាគទ្រង់បានធ្វើហេតុដែលបានបិទបាំងទុកក្នុងរវាងភព ឱ្យប្រាកដ ។

ក្នុងអតីតកាល ក្នុងកប្បទី ៥ អំពីភទ្ទកប្បនេះ ព្រះបរមពោធិសត្វ បានកើតជាឈ្មួញដើរទិញរបស់ចាស់ៗ និងលក់នូវរបស់ផ្សេងៗ តាមភូមិស្រុក។ ព្រះបរមពោធិសត្វក្នុងកាលនោះមានឈ្មោះថា **សេរិវៈ** នៅក្នុងដែនសេរិវរដ្ឋ ។ គ្រាមួយ កាលដែលទៅធ្វើជំនួញ បានទៅជាមួយនឹងឈ្មួញឡេះឡោះម្នាក់ ឈ្មោះសេរិវៈ ដូចគ្នា ។ បានឆ្លងទន្លេឈ្មោះនីលពាហៈ ហើយចូលទៅកាន់ព្រះនគរឈ្មោះថា អរិដ្ឋបុរៈ ទើបបែកផ្លូវគ្នាដើរលក់អីវ៉ាន់ ។ ក្នុងព្រះនគរនោះ មានត្រកូលសេដ្ឋីមួយ ដែលបុត្រនិងបងប្អូន ព្រមទាំងទ្រព្យសម្បត្តិទាំងពួង បានស្លាប់និងបាត់បង់អស់ទៅហើយ នៅឡើយតែក្មេងស្រីម្នាក់ជាមួយនឹងជីដូន ។ ជីដូននិងចៅ ត្រូវស៊ីឈ្នួលគេដើម្បីចិញ្ចឹមជីវិត ។ នៅក្នុងផ្ទះ បានមានថាសមាសដែលមហាសេដ្ឋី



របស់យាយនិងចៅនោះ ធ្លាប់ប្រើប្រាស់ ហើយទុកជាមួយនឹងភាជនៈដទៃៗ កាលដែលមិនបានប្រើប្រាស់យូរៗទៅ ក្អែលខ្មៅៗក៏ចាប់កាន់ទៅជាស្នឹម ដែលធ្វើឱ្យយាយនិងចៅមិនដឹងថាគឺជាថាសមាសឡើយ ។

សម័យនោះ ឈ្មួញឡេះឡោះ បានដើរស្រែកលក់របស់ រហូតទៅដល់ខ្លោងទ្វារផ្ទះនោះ ។ កុមារិកា បានឃើញឈ្មួញលក់របស់ មានប្រដាប់សម្រាប់ខ្លួនលេង ក៏ពោលនឹងជីដូនថា យាយ សូមយាយទិញប្រដាប់នោះឱ្យចៅ ។ យាយពោលថា ចៅអើយ យើងជាអ្នកក្រ បានអ្វីទៅទិញ ។ ចៅស្រីពោលថា យើងមានថាសនេះ ទុកទៅក៏មិនបានប្រយោជន៍ដល់យើងដែរ ចូរយាយឱ្យថាសនេះដូរយកគ្រឿងប្រដាប់ឱ្យចៅ ។ យាយទើបឱ្យហៅនាយពាណិជមកហើយ ឱ្យអង្គុយលើអាសនៈ បានឱ្យថាសមាសនោះ ហើយពោលថា នាយ អ្នកចូរយកថាសនេះ ហើយឱ្យគ្រឿងប្រដាប់អ្វីៗ ដល់ចៅស្រីរបស់អ្នក នេះលេងផងណ៎ា! អ្នក ។ នាយពាណិជ យកដៃចាប់ថាស

នោះហើយ គិតថាវាជាថាសមាស ទើបត្រឡប់ថាសផ្កាប់យកម្ជុលឆ្វូតបាតថាស ដឹងច្បាស់ថាជាមាស ទើបគិតថាយើងនឹងមិនឱ្យអ្វីៗដល់មនុស្សទាំងនេះឡើយ នឹងនាំយកថាសនេះទៅ ហើយពោលថា ថាសនេះវាមិនមានតម្លៃអ្វីទេ សូម្បីតែកន្លះមាសកក៏មិនបានផង ។ ឈ្មួញកំហូចបានបោះថាសមាសទៅលើដី ហើយក្រោកចាកអាសនៈចៀសចេញទៅ ។

ព្រះបរមពោធិសត្វ បានដើរលក់របស់របរនោះៗរហូតទៅប្រសព្វគ្នានឹងផ្លូវ ដែលនាយពាណិជឡេះឡោះកំហូចបានដើរ ទើបចូលទៅកាន់ផ្លូវនោះ ស្រែកលក់របស់ថា ចូរកាន់យកនូវគ្រឿងប្រដាប់ ដូច្នេះ ហើយបានទៅដល់ខ្លោងទ្វារផ្ទះនោះឯង ។ កុមារិកានោះ បានពោលនឹងជីដូន ដូចមុនទៀត ។ លំដាប់នោះ យាយបានពោលនឹងចៅថា ចៅអើយ ឈ្មួញដែលមកដល់ផ្ទះនេះបានបោះថាសនោះចោលទៅនឹងដីហើយ ឥឡូវនេះយើងបានអ្វីឱ្យគេទៀត ដើម្បីបានគ្រឿងប្រដាប់ ។ ចៅពោល



ថា យាយអើយ ឈ្មួញមុននោះ និយាយសំឡេងគ្រោត-គ្រាតណាស់ ចំណែកឥឡូវនេះ ឈ្មួញនេះ គួរឱ្យស្រឡាញ់និយាយដោយសំឡេងទន់ភ្លន់ គាត់មុខតែទទួលយកមិនខាន ។ យាយពោលថា បើដូច្នោះ ចៅហៅគាត់មក ។ ចៅស្រីក៏បានស្រែកហៅនាយពាណិជ ដែលជាព្រះបរម-ពោធិសត្វ ។ លំដាប់នោះ យាយនិងចៅ បានយកថាសមាសនោះឱ្យដល់ព្រះបរមពោធិសត្វ ដែលបានចូលមកអង្គុយក្នុងផ្ទះ ។ ព្រះបរមពោធិសត្វ ដឹងថាជាថាសមាសទើបពោលថា ម៉ែ ថាសនេះ មានតម្លៃដល់ទៅសែនកហាបណៈ ឯរបស់ដែលមានតម្លៃស្មើនឹងថាសនេះ មិនមានក្នុងដៃរបស់ខ្ញុំបាទឡើយ ។ យាយនិងចៅ ទើបពោលថា នែនាយដ៏មានបុណ្យអើយ នាយពាណិជដែលមកមុននេះបានពោលថា ថាសនេះមានតម្លៃមិនដល់កន្លះមាសកផង ហើយគ្រវែងថាសនេះចោលទៅនឹងដី ប៉ុន្តែថាសនេះ បានកើតជាថាសមាស ព្រោះបុណ្យរបស់លោក ពួកយើងឱ្យថាសនេះដល់លោក លោកឱ្យអ្វីៗដល់

ពួកយើងក៏បានដែរ ។ ខណៈនោះ ព្រះបរមពោធិសត្វ ទើបឱ្យកហាបណៈ ៥០០ ដែលមាននៅនឹងដៃ ព្រមទាំងគ្រឿងរបស់ទាំងអស់ដែលមានតម្លៃស្មើនឹង ៥០០ កហាបណៈផងដែរ សូមទុកត្រឹមតែប៉ុណ្ណេះថា អ្នកទាំងពីរចូរឱ្យជញ្ជីងនិងបាវ ព្រមទាំងកហាបណៈ ៨ កហាបណៈ ដល់ខ្ញុំបាទ រួចហើយក៏បានកាន់យកថាសនោះឯង រួតរះទៅកាន់កំពង់ទឹក ។ ព្រះបរមពោធិសត្វ ឱ្យម្ចាស់ទូក ៨ កហាបណៈ ហើយក៏ឡើងទូកទៅ ។

ចំណែកនាយពាណិជ ដែលជាជនពាលបានត្រឡប់ទៅផ្ទះនោះទៀត ហើយពោលថា អ្នកចូរនាំថាសនោះមក យើងនឹងឱ្យរបស់ខ្លះ ។ ស្ត្រីនោះ បានបរិភាសតិះដៀលនាយឈ្មួញពាលនោះហើយពោលថា អ្នកឯងបានធ្វើថាសមាសដែលមានតម្លៃមួយសែនរបស់យើង ឱ្យមានតម្លៃមិនបានកន្លះមាសកផង ប៉ុន្តែនាយពាណិជម្នាក់ដែលមានធម៌ បានឱ្យទ្រព្យយើងមួយពាន់ ហើយកាន់យកថាសមាសនោះទៅហើយ ។ នាយពាណិជកំហូចបានស្តាប់



ដូច្នោះហើយ គិតថា យើងជាអ្នកវិនាសចាកថាសមាសដែលមានតម្លៃមួយសែន ពាណិជនោះបានធ្វើសេចក្តីវិនាសដ៏ធំឱ្យដល់យើងហ្ន៎ រួចហើយពាណិជកំហូច កើតសេចក្តីសោកដ៏មានកម្លាំង មិនអាចតាំងស្មារតីបាន ក៏ដួលសន្លប់ទៅនឹងដី ដឹងខ្លួនឡើងវិញ បានចោលកហាបណៈដែលនៅនឹងដៃ ព្រមទាំងអីវ៉ាន់ទាំងអស់ នៅនឹងមុខផ្ទះនោះឯង ចោលទាំងសំពត់ស្លៀកដណ្តប់ កាន់តែដងជញ្ជីងធ្វើជាដំបង រត់ទៅតាមស្នាមជើងព្រះបរមពោធិសត្វ ។ ទៅដល់មាត់ទន្លេ ឃើញព្រះបរមពោធិសត្វកំពុងទៅហើយ ទើបពោលថា នែម្ចាស់ទូកដ៏ចម្រើន អ្នកចូរត្រឡប់ទូក ។ ព្រះបរមពោធិសត្វ ហាមថា កុំត្រឡប់។

ជនពាលជាពាណិជ ឃើញព្រះបរមពោធិសត្វទៅហើយ កើតសេចក្តីសោកដ៏ខ្លាំងក្លា ហឫទ័យក្តៅផ្សា ក្អួតឈាមស្រស់ៗ ហើយចងអាឃាតនឹងព្រះបរមពោធិសត្វដល់នូវការអស់ជីវិតក្នុងទីនោះឯង ។ នេះជាការចងអាឃាតនឹងព្រះបរមពោធិសត្វនៃព្រះទេវទត្តជាគ្រាដំបូង ។

ព្រះបរមពោធិសត្វ ធ្វើបុណ្យមានទានជាដើម ហើយក៏បានទៅតាមយថាកម្ម ។

ព្រះសម្មាសម្ពុទ្ធ កាលដែលព្រះអង្គត្រាស់នូវព្រះធម៌ទេសនានេះហើយ ទ្រង់បានត្រាស់សម្ដែងនូវព្រះគាថានេះថា :

**ឥធ ចេ នំ វិរាធេសិ សទ្ធម្មស្ស និយាមកំ**
**ចិរំ ត្វំ អនុតប្បេសិ សេរិវាយំវ វាណិជោតិ។**

បើអ្នកធ្វើឱ្យឃ្លាតចាកនូវសោតាបត្តិមគ្គ ជាគ្រឿងកំណត់នូវព្រះសទ្ធម្មនោះក្នុងព្រះសាសនានេះហើយ អ្នកនឹងក្ដៅក្រហាយរឿយៗ អស់កាលដ៏យូរ ដូចជាពាណិជឈ្មោះ សេរិវៈនេះ ដូច្នោះឯង ។

បណ្ដាបទទាំងនោះ បទថា **ឥធ ចេ នំ វិរាធេសិ សទ្ធម្មស្ស និយាមកំ** ដោយសេចក្ដីថា បើអ្នកឃ្លាតចាកអំពីសោតាបត្តិមគ្គ ពោលគឺភាពដ៏ពិតប្រាកដនៃព្រះសទ្ធម្មយ៉ាងនេះ ក្នុងព្រះសាសនានេះ ។ អធិប្បាយថា កាលបើអ្នកលះបង់នូវសេចក្ដីព្យាយាម អ្នកនឹងមិនបានសម្រេច ។



បទថា **ចិរំ ត្វំ អនុតប្បេសិ** ដោយសេចក្ដីថា កាលបើដូច្នោះ អ្នករមែងសោយសោក ហើយនឹងក្ដៅក្រហាយក្នុងកាលជាខាងក្រោយ រហូតអស់កាលយូរ ។ ក្នុងបទនេះមានសេចក្ដីអធិប្បាយថា អ្នកកើតក្នុងនរកជាដើម សោយទុក្ខមានប្រការផ្សេងៗ អស់កាលជាអង្វែង ។ ដែលថានឹងក្ដៅក្រហាយចិត្តក្នុងកាលជាខាងក្រោយ គឺថានឹងលំបាក ព្រោះភាពជាអ្នកលះបង់នូវសេចក្ដីព្យាយាម ធ្វើឱ្យឃ្លាងចាកអំពីអរិយមគ្គ ។ សួរថា តើនឹងក្ដៅក្រហាយក្នុងកាលជាខាងក្រោយយ៉ាងណា ? ឆ្លើយថា នឹងក្ដៅក្រហាយក្នុងកាលជាខាងក្រោយ ដូចនាយពាណិជឈ្មោះសេរិវៈ ។ លោកពោលពាក្យអធិប្បាយនេះទុកថា កាលមុន ពាណិជឈ្មោះសេរិវៈបានថាសមាសមានតម្លៃមួយសែន ប៉ុន្តែមិនធ្វើនូវសេចក្ដីព្យាយាម ដើម្បីនឹងកាន់យកថាសមាសនោះ ទើបវិនាសចាកថាសមាសនោះឯង ហើយក្ដៅក្រហាយក្នុងកាលជាខាងក្រោយ យ៉ាងណា សូម្បីអ្នកក៏ដូច្នោះដែរ កាលដែល

មិនបានសម្រេចនូវអរិយមគ្គ ដូចជាថាសមាសដែលគេត្រៀមទុកឱ្យ ក្នុងព្រះសាសនានេះ ព្រោះលះបង់នូវសេចក្តីព្យាយាម ក៏ជាអ្នកវិនាសចាកអរិយមគ្គនោះ នឹងក្តៅក្រហាយក្នុងកាលជាខាងក្រោយ រហូតអស់កាលជាអង្វែង ។ ប្រសិនបើអ្នកមិនលះបង់នូវសេចក្តីព្យាយាមទេ អ្នកនឹងបានសម្រេចនូវលោកុត្តរធម៌គឺមគ្គទាំង ៤ ក្នុងសាសនារបស់តថាគត ដូចនាយពាណិជដែលជាបណ្ឌិតបាននូវថាសមាសនោះ ដូច្នោះឯង ។

ព្រះបរមសាស្តា ទ្រង់កាន់យកនូវកំពូលធម៌គឺព្រះ-អរហត្ត សម្តែងព្រះធម៌ទេសនានេះ ដល់ភិក្ខុនោះ យ៉ាងដូច្នេះឯង ហើយទ្រង់ប្រកាសនូវសច្ចៈទាំង ៤ ។ ក្នុងវេលាចប់សច្ចកថា ភិក្ខុជាអ្នកលះបង់នូវសេចក្តីព្យាយាម ក៏បានតាំងនៅក្នុងព្រះអរហត្ត ដែលជាផលដ៏កំពូល ។ ព្រះអង្គទ្រង់ប្រជុំជាតកថា ពាណិជពាលក្នុងកាលនោះ បានជាភិក្ខុទេវទត្តក្នុងកាលនេះ ឯចំណែកនាយពាណិជដែលជាបណ្ឌិតក្នុងកាលនោះ បានជា **តថាគត** នេះឯង ។



## អត្ថគួរជ្រាប

ត្រូវស្មោះត្រង់នឹងខ្លួនឯង ស្មោះត្រង់នឹងអ្នកដទៃ ស្មោះត្រង់នឹងការងារក្នុងព្រះពុទ្ធសាសនា ។

-ស្មោះត្រង់នឹងខ្លួនឯង គឺរក្សាសេចក្តីល្អឱ្យខ្លួនឯង ។ សេចក្តីល្អមានសីលជាដើម ជាសិរីសួស្តីក្នុងជីវិត ។

-ស្មោះត្រង់នឹងអ្នកដទៃ គឺរក្សាសេចក្តីល្អរបស់ខ្លួន ដើម្បីបានជាប្រយោជន៍ដល់អ្នកដទៃ ។

-ស្មោះត្រង់នឹងការងារក្នុងព្រះពុទ្ធសាសនា គឺរក្សាសេចក្តីល្អរបស់ខ្លួន ដើម្បីបានជាប្រយោជន៍ដល់សីល សមាធិ បញ្ញា ។

មិនមានស្មោះត្រង់ក្នុងព្រះសាសនា
វិន័យធម៌អាចចំបាំងមុខបាំងក្រោយ
ទុកជាឡប់ឡែខ្លួនប្រែជាធ្លោយ
លាភយសនាំស៊យពេលក្រោយនឹងស្លាយ។

# ៥. មកសជាតក

(បិដកលេខ ៥៨ , ទំព័រ ២០ និងអដ្ឋកថា)

ព្រះបរមសាស្តា កាលដែលព្រះអង្គទ្រង់យាងទៅកាន់ភូមិអ្នកស្រុកមួយក្នុងដែនមគធៈ ទ្រង់ប្រារព្ធពួកមនុស្សមួយចំនួនក្នុងភូមិនោះ ជាបុគ្គលពាលល្ងង់ខ្លៅ ទើបព្រះអង្គទ្រង់ត្រាស់ព្រះធម៌ទេសនានេះថា **សេយ្យោ អមិត្តោ** ដូច្នេះជាដើម ។

បានស្តាប់មកថា ក្នុងសម័យមួយ ព្រះតថាគតព្រះអង្គយាងចេញចាកពីព្រះនគរសាវត្ថី ទៅកាន់ដែនមគធៈ ទ្រង់បានយាងទៅដល់ភូមិមួយ ។ ក្នុងភូមិនោះសម្បូណ៌ទៅដោយជនអន្ធពាល ។ ថ្ងៃមួយពួកមនុស្សអន្ធពាលទាំងនោះ ប្រជុំប្រឹក្សាគ្នាថា ម្នាលគ្នាយើង ពួកមូសវារោមខាំយើង ពេលដែលយើងទៅធ្វើការនៅក្នុងព្រៃ ព្រោះហេតុនោះ ការងាររបស់យើង ត្រូវបានខាត



បង់ដោយច្រើន ដូច្នេះពួកយើងត្រូវនាំយកធ្នូនិងអាវុធផ្សេងៗទៀត ឱ្យគ្រប់ដៃ នាំគ្នាទៅច្បាំងជាមួយហ្វូងមូស បាញ់សម្លាប់និងកាប់ចាក់ឱ្យពួកវាស្លាប់អស់ រួចហើយក៏នាំគ្នាទៅព្រៃ ។ ពួកជនល្ងង់ខ្លៅទាំងនោះ នាំគ្នាសំដៅទៅរកសម្លាប់មូស បាញ់កាប់ចាក់សំពង ត្រឡប់ទៅជាប្រហារចំគ្នាឯង ទៅវិញទៅមក ។ គ្រប់គ្នាត្រូវរបួសឈឺចាប់ត្រឡប់មកផ្ទះវិញ ដេកនៅក្នុងភូមិក៏មាន កណ្តាលភូមិក៏មាន មាត់ទ្វារភូមិក៏មាន ។ ព្រះបរមសាស្តា ហែហមដោយព្រះភិក្ខុសង្ឃ ស្តេចចូលទៅកាន់ភូមិនោះដើម្បីបិណ្ឌបាត ។ ពួកមនុស្សដែលជាបណ្ឌិត បានឃើញព្រះដ៏មានព្រះភាគហើយ ទើបសាងមណ្ឌបនៅឯមាត់ទ្វារភូមិថ្វាយមហាទានដល់ព្រះភិក្ខុសង្ឃ មានព្រះសម្មាសម្ពុទ្ធជាប្រមុខ ថ្វាយបង្គំព្រះសាស្តា នាំគ្នាអង្គុយក្នុងទីដ៏សមគួរ។ គ្រានោះ ព្រះបរមសាស្តា ទតព្រះនេត្រឃើញមនុស្សទាំងឡាយ ដួលដេកឈឺចាប់ក្នុងទីនោះៗ ក៏ត្រាស់សួរឧបាសកទាំងនោះថា មនុស្សទាំងនេះទៅធ្វើអ្វីគ្នា ទើប

មកដេកឈឺចាប់ដោយមុខរបួសដូច្នេះ ? ឧបាសកទាំង-នោះ ទើបក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន មនុស្សទាំងនេះបបួលគ្នាថា ពួកយើងនឹងទៅច្បាំងជាមួយហ្វូងមូស ហើយក៏លើកគ្នាទៅ តែបែរជាទៅច្បាំងគ្នាឯងហើយក៏ដល់នូវការឈឺចាប់ដូច្នេះ ព្រះអង្គ ។ ព្រះដ៏មាន-ព្រះភាគទ្រង់ត្រាស់ថា មិនមែនតែក្នុងពេលនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន ក៏ធ្លាប់មានមនុស្សគិតថា យើងនឹងប្រហារមូស តែត្រឡប់ទៅជាប្រហារអ្នកដទៃវិញ ដូចគ្នាដែរ ។ កាលដែលពួកឧបាសកទាំងនោះ ទូលអារាធនាហើយ ទ្រង់ក៏បាននាំយករឿងក្នុងអតីតកាលមកសម្តែងដូចតទៅ :

ក្នុងអតីតកាល ពេលដែលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះបរមពោធិសត្វ មានអាជីពជាអ្នកជំនួញ ។ សម័យនោះ នៅនឹងភូមិជាយដែនមួយ ក្នុងដែនកាសី មានពួកជាងឈើអាស្រ័យនៅដោយច្រើនជាមួយគ្នា ។ មានជាងឈើក្បាលតម្លែកម្នាក់ ក្នុង



ពួកជាងឈើទាំងនោះ កំពុងតែដាប់ដៃធ្វើការ ខណៈនោះមានមូសមួយបានហើរមកខាំត្រង់ក្បាលរបស់គាត់ ។ ជាងឈើទើបប្រាប់កូនរបស់ខ្លួន ដែលអង្គុយនៅជិតគាត់នោះឯងថា នែកូន មូសវាខាំក្បាលឪ ឈឺដូចគេចាក់ដោយលំពែងអីចឹង ចូរកូនសម្លាប់វាឱ្យឪមើល៍ ! កូននិយាយថាឪចូរនៅឱ្យស្ងៀម កូននឹងសម្លាប់វា ដោយការប្រហារតែម្តងប៉ុណ្ណោះ ។ កូននិយាយរួចហើយ ក៏លើកពូថៅផ្លែធំឡើង យារតម្រង់មូស ឈរនៅពីក្រោយឪ កាប់ពេញទំហឹងដៃ ដោយគិតថា អញនឹងសម្លាប់មូសនេះ ។ ក្បាលរបស់ឪក៏ត្រូវបែកដាច់ជាពីរ ស្លាប់ទៅក្នុងទីនោះឯង ។ ពេលនោះព្រះបរមពោធិសត្វ ដែលកំពុងឈប់សម្រាកនៅក្នុងរោងជាងឈើនោះ បានឃើញអំពើរបស់កូនជាងឈើហើយ បានគិតថា បើបច្ចាមិត្តនោះជាបណ្ឌិតក៏នៅប្រសើរជាង ព្រោះគេមានការកោតក្រែងអាជ្ញាក្នុងព្រះនគរ មិនដល់ថ្នាក់សម្លាប់មនុស្សឡើយ ហើយព្រះ-បរមពោធិសត្វបានពោលនូវគាថានេះថា :

**សេយ្យោ អមិត្តោ មតិយា ឧបេតោ**

**ន ត្វេវ មិត្តោ មតិវិប្បហីនោ**

**មកសំ វធិស្សន្តិ ហិ ឯលមូគោ**

**បុត្តោ បិតុ អព្ភិទា ឧត្តមង្គន្តិ ។**

បុគ្គលជាសត្រូវ តែប្រកបដោយប្រាជ្ញា ប្រសើរជាង ឯបុគ្គលជាមិត្ត ដែលប្រាសចាកប្រាជ្ញាមិនប្រសើរឡើយ ដូចយ៉ាងកូនបង្កើតដែលល្ងង់ខ្លៅ គិតថាអញនឹងសម្លាប់មូស ត្រឡប់ជាពុះបំបែកក្បាលឪទៅវិញ ។

បណ្ដាបទទាំងនោះ បទថា **សេយ្យោ** ដោយសេចក្ដីថា ប្រសើរ គឺខ្ពង់ខ្ពស់បំផុត ។

បទថា **មតិយា ឧបេតោ** ដោយសេចក្ដីថា ប្រកបដោយបញ្ញា ។

បទថា **ឯលមូគោ** ប្រែថា ល្ងីល្ងើ គឺល្ងង់ខ្លៅ ។

បទថា **បុត្តោ បិតុ អព្ភិទា ឧត្តមង្គំ** ដោយសេចក្ដីថា ព្រោះភាពនៃខ្លួនជាមនុស្សល្ងង់ខ្លៅ សូម្បីជា



កូន គិតថាយើងនឹងសម្លាប់មូស ក៏ញាំងក្បាលឪពុកឱ្យបែកជាពីរ ព្រោះហេតុនោះ បណ្ឌិត សូម្បីតែជាសត្រូវ ក៏នៅល្អជាងមិត្តដែលល្ងង់ល្ងីល្ងើ ។

ព្រះបរមពោធិសត្វ កាលដែលពោលនូវគាថានេះហើយ ក៏ក្រោកឡើងទៅធ្វើការងារតាមតួនាទី ។ ឯពួកញាតិរបស់អ្នកស្លាប់ ក៏បានចាត់ការធ្វើសរីរកិច្ចរបស់ជាងឈើដែលបានទទួលមរណភាពនោះឯង ។

ព្រះបរមសាស្ដា ព្រះអង្គត្រាស់ថា ម្នាលអ្នកទាំង-ឡាយ សូម្បីក្នុងកាលមុន ក៏ធ្លាប់មានមនុស្សដែលបានគិតថា យើងនឹងប្រហារមូស តែត្រឡប់ជាប្រហារអ្នកដទៃវិញ ដូចគ្នាដែរ ។ កាលដែលទ្រង់នាំយកព្រះធម៌ទេសនានេះមកសម្ដែងហើយ ព្រះអង្គក៏បន្តអនុសន្ធិប្រជុំជាតកថា ឈ្មួញបណ្ឌិតដែលពោលគាថាហើយចេញទៅ បានមកជា **តថាគត** នេះឯង ។

**(ចប់មកសជាតក)**

## អត្ថគួរជ្រាប

គួរខ្លាចសេចក្តីល្ងង់របស់ខ្លួនឯង ជាងខ្លាចសេចក្តីល្ងង់នៃអ្នកដទៃ ព្រោះថា បុគ្គលល្ងង់ខ្លៅជាកំពូលសត្រូវនឹងខ្លួនឯង ។

មនុស្សល្ងង់ មិនដឹងហេតុនៃផល មិនដឹងផលរបស់ហេតុ គិតថាធ្វើប្រយោជន៍ បែរទៅជាទម្លាយប្រយោជន៍ដែលមានហើយទៅវិញ ។ មនុស្សល្ងង់ រស់នៅជាមួយខ្លួនឯង តែមិនស្គាល់ខ្លួនឯង រស់នៅជាមួយអ្នកដទៃ តែមិនស្គាល់អ្នកដទៃ ដូចជាជន្លេនមិនស្គាល់ដី ត្រីមិនស្គាល់ទឹក ដូច្នោះឯង ។ មនុស្សល្ងង់មានចិត្ត តែមិនស្គាល់ចិត្ត គ្រប់គ្រងទូន្មានចិត្តរបស់ខ្លួនមិនបាន បែរទៅជាល្ងីល្ងើ ចង់គ្រប់គ្រងចិត្តអ្នកដទៃ ម្ល៉ោះហើយត្រូវកើតទុក្ខក្តៅក្រហាយ វឹងវៃ ព្រោះគ្រប់គ្រងមិនបាន ។



# ៦. ឃតាសនជាតក

(បិដកលេខ ៥៨ , ទំព័រ ៥៩ និងអដ្ឋកថា)

ព្រះវិជិតមារ កាលដែលទ្រង់គង់ប្រថាប់នៅនាព្រះជេតពនមហាវិហារ ទ្រង់ប្រារព្ធភិក្ខុមួយអង្គ ត្រាស់នូវព្រះធម៌ទេសនានេះថា **ខេមំ យហឹ** ដូច្នេះជាដើម ។

សេចក្តីពិស្តារថា ភិក្ខុនោះរៀនព្រះកម្មដ្ឋាន អំពីសម្នាក់ព្រះសាស្តា ហើយនិមន្តទៅកាន់ជាយដែន នាតំបន់មួយ ។ ភិក្ខុនោះ ចាំវស្សាមានសេនាសនៈក្នុងព្រៃអាស្រ័យភូមិអ្នកស្រុកមួយ ជាទីគោចរបិណ្ឌបាត ។ ក្នុងខែដំបូងនោះឯង កាលដែលលោកនិមន្តទៅបិណ្ឌបាត បណ្ណសាលាបានត្រូវភ្លើងឆេះ លោកលំបាកដោយមិនមានទីនៅ ទើបប្រាប់ដល់ពួកឧបដ្ឋាក ។ មនុស្សទាំងនោះនាំគ្នានិយាយថា មិនជាអ្វីឡើយ ព្រះគុណម្ចាស់ ពួកខ្ញុំ-ព្រះករុណានឹងសាងបណ្ណសាលាថ្វាយ ចាំដល់ពួកខ្ញុំព្រះ-

ករុណា ភ្ជួរស្រែរួច ។ ដល់ភ្ជួររួចហើយថា ចាំពួកខ្ញុំព្រះ-
ករុណាសាបព្រោះរួចសិនណា៎! ព្រះគុណម្ចាស់ ។ រហូត
បីខែកន្លងទៅ ព្រះភិក្ខុ លោកមិនអាចបំពេញព្រះកម្មដ្ឋាន
ឱ្យបានដល់ទីបំផុតឡើយ ព្រោះមិនមានសេនាសនៈជាទី
សប្បាយ ។ ដល់ចេញវស្សា លោកបាននិមន្តមកកាន់
ព្រះជេតពនមហាវិហារវិញ ថ្វាយបង្គំព្រះបរមសាស្តា
ហើយបានគង់អង្គុយក្នុងទីដ៏សមគួរ ។ ព្រះបរមសាស្តា
ទ្រង់បានធ្វើបដិសណ្ឋារៈចំពោះព្រះភិក្ខុ ហើយត្រាស់សួរ
ថា ម្នាលភិក្ខុ កម្មដ្ឋានរបស់អ្នកជាទីសប្បាយឬ ? ព្រះភិក្ខុ
បានក្រាបទូលអំពីការមិនស្រួល និងមិនសប្បាយដោយ
សេនាសនៈជាដើម ដល់ព្រះសាស្តា ។ ព្រះដ៏មានព្រះភាគ
ទ្រង់ត្រាស់ថា ម្នាលភិក្ខុ ក្នុងកាលមុននោះ សូម្បីសត្វ
តិរច្ឆានទាំងឡាយ ក៏ចេះស្គាល់សប្បាយនិងមិនសប្បាយ
របស់ខ្លួនដែរ ។ កាលដែលព្រះភិក្ខុក្រាបទូលអារាធនា
ទើបទ្រង់នាំយករឿងក្នុងអតីតមកសម្តែង ដូចតទៅ :

ក្នុងអតីតកាល គ្រាដែលព្រះបាទព្រហ្មទត្តសោយ



រាជសម្បត្តិក្នុងព្រះនគរពារាណសី ព្រះបរមពោធិសត្វ
កើតក្នុងកំណើតបក្សី មានរូបរាងស្អាតលើសគេ គឺជា
ស្តេចនៃបក្សីទាំងឡាយ អាស្រ័យនៅនឹងដើមឈើធំ
សម្បូណ៌ទៅដោយមែកសាខានិងមានប្រគាបល្អ ស្លឹកល្អ
ក្បែរមាត់ស្រះកើតឯងមួយ ។ ស្តេចបក្សី មានបរិវារច្រើន
កាលដែលអាស្រ័យនៅនឹងមែកឈើពីលើទឹកស្រះ ក៏នាំ
គ្នាបន្ទោបង់លាមកដាក់ទឹកស្រះនោះ ។ នៅក្នុងស្រះ
ដែលកើតឯងនោះ ក៏មាននាគរាជដ៏កាចសាហាវអាស្រ័យ
នៅ នាគរាជនោះបានគិតថា ពួកបក្សីទាំងនេះ នាំគ្នា
បន្ទោបង់លាមកដាក់ស្រះទឹក ដែលជាទីនៅរបស់យើង
ដូច្នេះ មានតែយើងធ្វើឱ្យភ្លើងឆេះឡើងពីទឹកដុតដើមឈើ
នោះចោល ឱ្យពួកវារត់ចេញទៅ ។ ស្តេចនាគនោះ មាន
ចិត្តក្រោធ នៅពេលពាក់កណ្តាលយប់ ដែលពួកបក្សី
ទាំងនោះ មកប្រជុំគ្នាដេកនៅនឹងមែកឈើទាំងឡាយ ក៏
ផ្តើមធ្វើឱ្យទឹកក្តៅ ប្រៀបបីដូចលើកស្រះទៅដាក់លើ
ចង្ក្រានដូច្នោះ តមកក៏ធ្វើឱ្យមានផ្សែងហុយឡើង រហូត

ដល់ធ្វើឱ្យមានអណ្តាតភ្លើងឆេះចេញឡើងពីទឹក ។ ព្រះ-បរមពោធិសត្វ ឃើញភ្លើងឆេះពីទឹក ក៏ពោលថា ម្នាលគ្នាយើងទាំងឡាយ ធម្មតាដែលភ្លើងឆេះឡើង គេតែងយកទឹកលត់ ប៉ុន្តែឥឡូវនេះ ទឹកនោះឯងបែរត្រឡប់ឆេះជាភ្លើង ពួកយើងមិនអាចនៅក្នុងទីនេះបានឡើយ ត្រូវនាំគ្នាទៅកាន់ទីដទៃ ហើយបានពោលនូវគាថានេះថា :

**ខេមំ យហឹ តត្ថ អរី ឧទីរិតោ**
**ឧទកស្ស មជ្ឈេ ជលតេ ឃតាសនោ**
**ន អជ្ជ វាសោ មហិយា មហីរុហេ**
**ទិសា ភជវ្ហោ សរណជ្ជ នោ ភយន្តិ ។**

សេចក្តីក្សេមក្សាន្តមាននៅលើខ្នងទឹកណា លើខ្នងទឹកនោះ មានសត្រូវកើតហើយ ព្រោះភ្លើងឆេះត្រង់ពាក់កណ្តាលនៃទឹក ។ ទីអាស្រ័យនៅនៃពួកយើង លើដើមឈើដែលដុះលើផែនដី ក្នុងថ្ងៃនេះ មិនមានទេ ។ អ្នកទាំងឡាយ ចូរទៅកាន់ទិសឯទៀតទៅ ថ្ងៃនេះ ភ័យកើតអំពីទីពឹងរបស់ពួកយើងហើយ ។



បណ្តាបទទាំងនោះ បទថា **ខេមំ យហឹ តត្ថ អរី ឧទីរិតោ** ដោយសេចក្តីថា សេចក្តីក្សេមគឺការដែលរួចផុតពីភ័យ មាននៅលើទឹកណា នៅលើទឹកនោះ មានសត្រូវមកបៀតបៀនហើយ ។

បទថា **ឧទកស្ស = ឧទកស្ស** ប្រែថា នៃទឹក ។

ភ្លើង ឈ្មោះថា **ឃតាសនៈ** អធិប្បាយថា ភ្លើងនោះរមែងស៊ីប្រេង ព្រោះហេតុនោះ ទើបលោកហៅថា **ឃតាសនៈ** ។

បទថា **ន អជ្ជ វាសោ** ដោយសេចក្តីថា ថ្ងៃនេះ ទីអាស្រ័យរបស់ពួកយើង មិនមានឡើយ ។

ក្នុងបទថា **មហិយា មហីរុហេ** នេះ ដើមឈើលោកហៅថា **មហីរុហោ** បានដល់ដើមឈើដែលកើតនៅលើផែនដីនេះ អធិប្បាយថា បក្សីទាំងឡាយ នៅលើដើមឈើនោះ ។

បទថា **ទិសា ភជវ្ហោ** ដោយសេចក្តីថា អ្នកទាំង-

ឡាយចូរគប់រក គឺនាំគ្នាហើរទៅកាន់ទិសផ្សេងទៀត ។

បទថា **សរណដ្ឋ នោ ភយំ** ដោយសេចក្ដីថា ថ្ងៃនេះ ភ័យកើតអំពីទីពឹងនៃពួកយើងហើយ គឺទីសម្នាក់របស់ពួកយើង កើតជាភ័យឡើងហើយ ។

ព្រះបរមពោធិសត្វ កាលដែលពោលយ៉ាងនេះហើយ ក៏នាំហ្វូងបក្សីដែលជឿស្ដាប់ពាក្យទូន្មាន ហើរទៅកាន់ទីដទៃ ពួកបក្សីដែលមិនជឿពាក្យទូន្មានរបស់ព្រះបរមពោធិសត្វ នាំគ្នាអាស្រ័យនៅ ដោយមិនបានហើរចេញឡើយ ក៏ដល់នូវការអស់ជីវិតក្នុងទីនោះទៅ ។

ព្រះបរមសាស្ដា កាលដែលព្រះអង្គនាំព្រះធម៌ទេសនានេះមកហើយ ទ្រង់ត្រាស់ប្រកាសសច្ចធម៌ ភិក្ខុអង្គនោះក៏តាំងនៅក្នុងព្រះអរហត្តផល ហើយទ្រង់ប្រជុំជាតកថា ហ្វូងបក្សីដែលធ្វើតាមពាក្យរបស់ព្រះបរមពោធិសត្វក្នុងគ្រានោះ បានមកជាពុទ្ធបរិស័ទ ចំណែកស្ដេចនៃពួកបក្សីនោះ បានមកជា **តថាគត** ដូច្នេះឯង ។

**(ចប់យសាសនជាតក)**



## អត្ថគួរជ្រាប

មហាភូតរូប ៤ , ឧបាទានក្ខន្ធ ៥ , កាមគុណ ៥ , លាភសក្ការៈ សេចក្ដីសរសើរ វត្ថុទាំងពួងក្នុងភព គឺជាទីអាស្រ័យដែលត្រូវភ្លើងទុក្ខ ភ្លើងកិលេសឆាបឆេះ ភ័យកើតអំពីទីពឹងទាំងនេះ ។

មនុស្សល្ងង់ ចង់តែផ្គាប់ចិត្តខ្លួនឯង ទើបមើលឃើញតែចំណុចអាក្រក់របស់គេ ហើយបៀតបៀនឱ្យគេវិនាស ។

មនុស្សល្ងង់មួយពួកទៀត ចចេស មិនស្ដាប់ការណែនាំតាមផ្លូវព្រះធម៌ ដែលបណ្ឌិតបានទូន្មាន ក៏ដល់នូវសេចក្ដីវិនាស ។

បណ្ឌិតជ្រាបច្បាស់នូវសច្ចធម៌ មិនផ្គាប់ចិត្តខ្លួនឯង មិនផ្គាប់ចិត្តអ្នកដទៃ ប្រកាសតែពីការពិត ហើយចេញពីភ័យទៅកាន់ទីក្សេមក្សាន្ត ។

# ៧. សូករជាតក

(បិដកលេខ ៥៨ , ទំព័រ ៦៩ និងអដ្ឋកថា)

ព្រះភគវា កាលដែលព្រះអង្គគង់ប្រថាប់នៅនាព្រះជេតពនមហាវិហារ ព្រះអង្គទ្រង់ប្រារព្ធព្រះថេរៈចាស់មួយអង្គ ត្រាស់នូវព្រះធម៌ទេសនានេះថា **ចតុប្បទោ អហំ សម្ម** ដូច្នេះជាដើម ។

សេចក្តីពិស្តារថា ក្នុងថ្ងៃមួយ ការស្តាប់ព្រះធម៌បានប្រព្រឹត្តទៅរហូតដល់ពាក់កណ្តាលនៃរាត្រី ព្រះបរមសាស្តា ទ្រង់ប្រថាប់ឈរលើផែនកែវមណី ជិតទ្វារព្រះគន្ធកុដិ ប្រទានសុគតោវាទដល់ពួកភិក្ខុហើយ ព្រះអង្គស្តេចទ្រង់ចូលកាន់ព្រះគន្ធកុដិ ។ ព្រះធម្មសេនាបតីសារីបុត្ត ថ្វាយបង្គំព្រះបរមសាស្តា ហើយបាននិមន្តទៅកាន់បរិវេណរបស់ខ្លួន ឯព្រះមហាមោគ្គល្លាន ក៏បាននិមន្តទៅកាន់បរិវេណរបស់ខ្លួនដែរ សម្រាកមួយសន្ទុះ ទើបនិមន្ត



មករកព្រះសារីបុត្ត ហើយសួរបញ្ហា ។ ព្រះធម្មសេនាបតីបានដោះស្រាយនូវបញ្ហា ដែលព្រះមហាមោគ្គល្លានសួរហើយ ជាបន្តបន្ទាប់ បានធ្វើឱ្យជាក់ច្បាស់ ដូចធ្វើព្រះចន្ទឱ្យប្រាកដនៅលើមេឃដូច្នោះឯង ។ ក្នុងសម័យនោះ ក៏មានបរិស័ទបួនជំពូក នៅអង្គុយស្តាប់ព្រះធម៌ផងដែរ ។ ពេលនោះ មានព្រះថេរៈចាស់មួយអង្គគិតថា អាត្មាអញនឹងញោះព្រះសារីបុត្ត សួរបញ្ហាកណ្តាលបរិស័ទ ម្យ៉ាងទៀតកាលបរិស័ទនេះដឹងថា អាត្មាអញជាពហុស្សូត ក៏នឹងធ្វើសក្ការៈ ព្រមទាំងលើកតម្កើង ។ ព្រះថេរៈចាស់បានក្រោកឡើងចាករវាងបរិស័ទ ចូលទៅរកព្រះសារីបុត្ត ហើយបានឈរនៅត្រង់កន្លែងមួយ ទើបពោលថា ម្នាលអាវុសោសារីបុត្ត ខ្ញុំព្រះករុណានឹងសួរបញ្ហាមួយចំពោះលោក សូមលោកឱ្យឱកាស ឱ្យការវិនិច្ឆ័យដល់ខ្ញុំព្រះករុណា ដោយអមក៏បាន ដោយត្រង់ក៏បាន ក្នុងការតិះដៀលក៏បាន ក្នុងការលើកតម្កើងក៏បាន ក្នុងសេចក្តីវិសេសក៏បាន មិនវិសេសក៏បាន ។ ព្រះធម្មសេនាបតី

សម្លឹងមើលព្រះថេរៈចាស់នោះហើយគិតថា ភិក្ខុចាស់នេះ តាំងនៅក្នុងសេចក្តីប្រណែន ល្ងង់ខ្លៅ មិនដឹងអ្វីសោះឡើយ ហើយក៏មិនបានមានព្រះថេរដីកាអ្វីនឹងភិក្ខុចាស់នោះដែរ ដាក់ផ្ចិតចុះ ក្រោកចាកអាសនៈចូលទៅកាន់បរិវេណ ។ សូម្បីព្រះមហាមោគ្គល្លាន ក៏បានចូលទៅកាន់បរិវេណនៃខ្លួនដូចគ្នាដែរ ។ ពួកមនុស្សនាំគ្នាក្រោកឡើងប្រកាសថា ពួកយើងចូរចាប់ភិក្ខុចាស់ចិត្តអាក្រក់នេះ ដែលបានធ្វើឱ្យពួកយើងខានស្តាប់ព្រះធម៌ដ៏ពីរោះដូច្នេះ ហើយក៏នាំគ្នាដេញតាមទៅ ។ ព្រះថេរៈចាស់នោះ បានរត់ទៅធ្លាក់ក្នុងវច្ចកុដិពេញដោយលាមក ព្រោះហេតុជាន់ក្តារបង្គន់បាក់ នៅខាងក្រោយឆ្ងាយពីវិហារ ហើយក្រោកឡើងមកទាំងដែលប្រឡាក់សុទ្ធតែលាមក ។ ពួកមនុស្សឃើញដូច្នោះ នាំគ្នារង្កៀស បានទៅគាល់ព្រះបរមសាស្តា ។

ព្រះបរមសាស្តា ទ្រង់ទតព្រះនេត្រឃើញមនុស្សទាំងអស់នោះ ទើបព្រះអង្គទ្រង់ត្រាស់សួរថា ឧបាសក



ឧបាសិកាទាំងឡាយ ពួកអ្នកទាំងឡាយមកធ្វើអ្វីខុសពេលវេលាដូច្នេះ ? ពួកមនុស្សទាំងនោះ បាននាំគ្នាក្រាបទូលសេចក្តីទាំងអស់ ដល់ព្រះដ៏មានព្រះភាគ ។ ព្រះបរម-សាស្តា ត្រាស់ថា ឧបាសកឧបាសិកាទាំងឡាយ ភិក្ខុចាស់នេះ វាយឫកក្រអឺត មិនដឹងកម្លាំងរបស់ខ្លួន ធ្វើការប្រៀបផ្ទឹមខ្លួនជាមួយនឹងអ្នកដែលមានកម្លាំងខ្លាំងក្លាក្រៃ-លែង ហើយបានធ្លាក់រណ្តៅលាមក មិនមែនត្រឹមតែក្នុងពេលនេះប៉ុណ្ណឹងទេ សូម្បីក្នុងកាលមុន ភិក្ខុចាស់នេះ ក៏ធ្លាប់វាយឫកក្អេងក្អាង មិនដឹងកម្លាំងរបស់ខ្លួន ធ្វើការប្រៀបផ្ទឹមខ្លួន ជាមួយនឹងអ្នកដែលមានកម្លាំងដ៏ខ្លាំងក្លា ហើយក៏ប្រឡាក់ខ្លួនក្នុងរណ្តៅលាមកដែរ ។ កាលឧបាសកនិងឧបាសិកាទាំងឡាយ ទូលអារាធនា ទើបទ្រង់នាំរឿងក្នុងអតីតកាលមកត្រាស់សម្តែងដូចតទៅ :

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តគ្រងរាជសម្បត្តិក្នុងព្រះនគរពារាណសី ព្រះបរមពោធិសត្វសោយព្រះ-ជាតិជារាជសីហ៍ អាស្រ័យនៅក្នុងគុហាភ្នំជិតហិមវន្តប្ប-

ទេស ។ ក្នុងទីមិនឆ្ងាយអំពីភ្នំនោះ មានជ្រូកដ៏ច្រើនអាស្រ័យនៅនឹងស្រះមួយ ឯព្រះតាបសទាំងឡាយក៏អាស្រ័យនឹងបណ្ណសាលាក្បែរស្រះនោះផងដែរ ។ ថ្ងៃមួយរាជសីហ៍បរិភោគអាហារគ្រប់គ្រាន់ហើយ បានចុះទៅកាន់ស្រះនោះ ឃើញជ្រូកធាត់មួយ ទើបគិតថា ថ្ងៃណាមួយយើងនឹងបរិភោគនូវជ្រូកនេះ ដើម្បីកុំឱ្យជ្រូកនេះផ្អើលលែងមកកាន់ទីនេះទៀត យើងត្រូវគេចទៅម្ខាងសិន ។ លុះរាជសីហ៍គិតដូច្នេះហើយ ទើបឡើងចាកស្រះគេចទៅផ្លូវម្ខាង ឯចំណែកជ្រូក ក៏បានសម្លឹងមើលឃើញរាជសីហ៍ហើយគិតថា រាជសីហ៍នេះ គ្រាន់តែឃើញយើងភ្លាម ក៏មិនហ៊ានចូលមកជិតឡើយ ព្រោះខ្លាចអំណាចយើង ហើយបានគេចខ្លួនចេញទៅ ថ្ងៃនេះ យើងគួរប្រយុទ្ធគ្នាជាមួយនឹងរាជសីហ៍នេះ ។ ជ្រូកគិតដូច្នេះហើយ ទើបស្រែកហៅរាជសីហ៍ ឱ្យមកតស៊ូជាមួយគ្នាដោយពាក្យដូច្នេះថា :

ម្នាលសម្លាញ់ យើងមានជើង ៤ ឯអ្នកក៏មានជើង



៤ ដូចគ្នាដែរ អ្នកចូរត្រឡប់មកប្រយុទ្ធគ្នាសិន អ្នកខ្លាចយើងឬទើបគេចទៅដូច្នេះ ។

រាជសីហ៍បានស្ដាប់ពាក្យរបស់ជ្រូកហើយ ទើបពោលថា ម្នាលជ្រូកសម្លាញ់ ថ្ងៃនេះ យើងមិនប្រយុទ្ធជាមួយអ្នកទេ ចាំ ៧ ថ្ងៃទៀតចុះ សឹមមកប្រយុទ្ធគ្នានៅទីនេះ ហើយក៏គេចទៅ ។ ជ្រូករីករាយសប្បាយចិត្តណាស់ ព្រោះខ្លួននឹងបានប្រយុទ្ធជាមួយរាជសីហ៍ ទើបពោលរឿងនោះឱ្យដល់ពួកញាតិស្ដាប់ ។ ពួកញាតិស្ដាប់ហើយ នាំគ្នាតក់ស្លុតភ័យខ្លាច និយាយឡើងថា អ្នកឯងនាំពួកយើងទាំងអស់គ្នា ឱ្យដល់នូវសេចក្ដីវិនាសគ្រានេះហើយ អ្នកឯងមិនដឹងកម្លាំងរបស់ខ្លួន ទើបប្រាថ្នាប្រយុទ្ធជាមួយនឹងរាជសីហ៍ រាជសីហ៍នឹងមកធ្វើឱ្យយើងទាំង-អស់ដល់នូវសេចក្ដីស្លាប់ ។ ជ្រូកម្ចាស់ខ្លួន ក៏ភ័យតក់ស្លុតហើយពោលថា ឥឡូវនេះ ឱ្យខ្ញុំធ្វើដូចម្ដេចទើបល្អ ។ ជ្រូកជាញាតិបានប្រាប់ថា អ្នកឯងចូរទៅកាន់ទីបន្ទោបង់លាមកនៃពួកតាបស ចុះប្រឡាក់ខ្លួននឹងលាមកឱ្យសើម

ជោក ហើយនៅរង់ចាំឱ្យខ្លួនស្ងួត ៧ ថ្ងៃ ដល់ថ្ងៃទី ៧ ចូរអ្នកឯងធ្វើខ្លួនឱ្យសើមដោយទឹកសន្សើម ហើយទៅកាន់ទីប្រយុទ្ធមុនរាជសីហ៍ ចូរសង្កេតមើលខ្យល់ គឺអ្នកឯងត្រូវឈរនៅពីលើខ្យល់ ព្រោះថារាជសីហ៍ជាសត្វស្អាតនឹងធុំក្លិនស្អុយខ្លួនរបស់អ្នកហើយ នឹងប្រគល់ជ័យជម្នះឱ្យអ្នកឯង ។ ជ្រូកបានធ្វើតាមពាក្យរបស់ពួកញាតិ ក្នុងថ្ងៃទី ៧ ក៏បានទៅកាន់ទីប្រយុទ្ធ ។ រាជសីហ៍បានធុំក្លិនគូប្រយុទ្ធ ក៏ដឹងថា ខ្លួនជ្រូកប្រឡាក់សុទ្ធតែលាមក ទើបពោលថា ម្នាលសម្លាញ់ជ្រូក អ្នកគិតដោយឧបាយល្អណាស់ ប្រសិនបើអ្នកមិនប្រឡាក់លាមកទេ យើងនឹងសម្លាប់អ្នកត្រង់នេះ ប៉ុន្តែឥឡូវនេះ យើងមិនអាចខាំខ្លួនអ្នកដោយមាត់ ជាន់ខ្លួនអ្នកដោយជើងបានឡើយ យើងឱ្យអ្នកឈ្នះហើយ ទើបពោលនូវគាថា :

**អសុចិ បូតិលោមោសិ ទុគ្គន្ធោ វាសិ សូករ**
**សចេ យុជ្ឈិតុកាមោសិ ជយំ សម្ម ទទាមិ តេតិ។**

ម្នាលសូករ អ្នកមានកាយស្មោកគ្រោក មានរោម



ប្រឡាក់ដោយវត្ថុស្អុយ មានក្លិនអាក្រក់បក់ទៅ បើអ្នកចង់ច្បាំងគ្នា ម្នាលសម្លាញ់ យើងឱ្យជ័យជម្នះដល់អ្នក ។

ក្នុងបណ្តាបទទាំងនោះ បទថា **បូតិលោមោសិ** បានដល់ រោមមានក្លិនស្អុយ ព្រោះប្រឡាក់ដោយលាមក។

បទថា **ទុគ្គន្ធោ វាយសិ** (បិដក= **វាសិ**) គឺមានក្លិន បដិកូលគួរខ្ពើមដ៏ក្រៃលែង បក់ផ្សាយចេញទៅ។

បទថា **ជយំ សម្ម ទទាមិ តេ** បានដល់ យើងឱ្យអ្នកឈ្នះ ។

រាជសីហ៍ កាលដែលពោលថា យើងចាញ់ហើយ អ្នកចូរទៅចុះ ដូច្នេះហើយក៏ត្រឡប់ចាកអំពីទីនោះ ទៅរកអាហារ ផឹកទឹកក្នុងស្រះ ចូលទៅកាន់គុហាភ្នំវិញទៅ។ ឯចំណែកជ្រូក បានត្រឡប់ទៅប្រាប់ពួកញាតិថា យើងឈ្នះរាជសីហ៍ហើយ ។ ពួកជ្រូកទាំងនោះ នាំគ្នាតក់ស្លុតខ្លាចថារាជសីហ៍នឹងត្រឡប់មកនៅថ្ងៃណាមួយទៀត រួចហើយនឹងសម្លាប់ពួកយើងស្លាប់អស់ ទើបនាំគ្នារត់ទៅកាន់ទីដទៃ ។

ព្រះបរមសាស្តា កាលដែលព្រះអង្គទ្រង់នាំព្រះ-ធម៌ទេសនានេះមកហើយ ព្រះអង្គប្រជុំជាតកថា ជ្រូកប្រឡាក់លាមកក្នុងកាលនោះ បានមកជាភិក្ខុចាស់ក្នុងគ្រានេះ ចំណែករាជសីហ៍ បានមកជា **តថាគត** នេះឯង ។

(ចប់សូករជាតក)

### អត្ថគួរជ្រាប

បាបរមែងប្រឡាក់នូវអ្នកធ្វើបាប ។

**ហិរិ** ប្រែថាខ្មើមបាប ឃើញបាបដូចជាលាមក ។

មនុស្សល្ងង់ តែងឆក់ឱកាសគិតថាខ្លួនឯងអស្ចារ្យ និងចង់ឈ្នះអ្នកដទៃ ទីបំផុតត្រូវលំបាកខ្លួន ចាញ់ទាំងខ្លួនឯង ចាញ់ទាំងធម្មជាតិ ។ បណ្ឌិត មិនគិតថាខ្លួនឯងអស្ចារ្យអ្វីឡើយ មិនគិតយកប្រៀបលើអ្នកដទៃ ហើយក៏មិនគិតថាចាញ់ប្រៀបគេដែរ មានចិត្តស្ងប់រំងាប់ ឃើញអ្វីៗជាធម្មជាតិម្យ៉ាងៗ ទៅតាមហេតុដែលមាន ។



## ៨-  មាតុបោសកជាតក

(បិដកលេខ ៥៩ , ទំព័រ ២១០ និងអដ្ឋកថា)

ព្រះបរមសាស្តា កាលដែលព្រះអង្គទ្រង់គង់ប្រថាប់នៅនាព្រះជេតពនមហាវិហារ ទ្រង់បានប្រារព្ធភិក្ខុអ្នកចិញ្ចឹមមាតា ទើបត្រាស់នូវព្រះធម៌ទេសនានេះថា **តស្ស នាគស្ស វិប្បវាសេន** ដូច្នេះជាដើម ។

រឿងបច្ចុប្បន្ន ដូចគ្នានឹងរឿងសុវណ្ណសាមនោះឯង ។ ព្រះបរមសាស្តា ត្រាស់ហៅភិក្ខុទាំងឡាយមកហើយ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកទាំង-ឡាយកុំឱ្យលើកទោសភិក្ខុនេះឡើយ បណ្ឌិតទាំងឡាយពីបុរាណ សូម្បីកើតក្នុងកំណើតសត្វតិរច្ឆាន កាលដែលព្រាត់ចាកពីមាតា ក៏មានខ្លួនស្គាំងស្គម ព្រោះអត់អាហារ ៧ ថ្ងៃ ទោះបីបានភោជនដ៏សមគួរដល់ព្រះរាជាក៏ដោយ ក៏គិតថា យើងព្រាត់ចាកមាតាហើយ នឹងមិនបរិភោគ

ឡើយ ។ កាលដែលភិក្ខុអារាធនាហើយ ព្រះអង្គទើបនាំអតីតនិទានមកសម្ដែង ដូចតទៅ :

ក្នុងអតីតកាល កាលដែលព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិ ក្នុងក្រុងពារាណសី គ្រានោះ ព្រះ-បរមពោធិសត្វ កើតក្នុងកំណើតដំរី ក្នុងដែនដីនៃព្រៃហិមពាន្ត មានសម្បុរសស្គុស រូបរាងស្អាតគួរស្រឡាញ់ និងគួរជ្រះថ្លា សម្បូណ៌ដោយលក្ខណៈ និងមានដំរី ៨០ ពាន់ជាបរិវារ ។ ចំណែកមាតារបស់ព្រះបរមពោធិសត្វ ជាដំរីងងឹតភ្នែក ។ ព្រះបរមពោធិសត្វ បានឱ្យផ្លែឈើមានរសឆ្ងាញ់ដល់ដំរីទាំងឡាយ បញ្ជូនទៅកាន់សម្នាក់នៃមាតា ដំរីទាំងឡាយ មិនបានឱ្យដល់មាតាឡើយ ទំពាស៊ីខ្លួនឯងអស់ ។ ព្រះបរមពោធិសត្វ កំណត់ដឹងរឿងនោះ ក៏គិតថា យើងនឹងលះបង់ពួកហ្វូងហើយចិញ្ចឹមតែមាតាប៉ុណ្ណោះ ។ លុះដល់ពេលយប់ កាលដែលដំរីដទៃមិនបានដឹង ទើបនាំមាតាទៅកាន់ជើងភ្នំ ឈ្មោះថា ចណ្ឌោរណៈហើយទុកដាក់មាតានៅនឹងគុហាភ្នំ ដែលជា



ភ្នំជាប់ជួរគ្នាមកចុងម្ខាងទៀត ឆ្ងាយពីគ្នា ហើយចិញ្ចឹមមើលថែ ។

សម័យនោះមានព្រានព្រៃម្នាក់អ្នកក្រុងពារាណសី បានវង្វេងផ្លូវ កាលដែលមិនអាចកំណត់ទិសបាន ទើបស្រែកយំដោយសំឡេងខ្លាំងៗ ។ ព្រះបរមពោធិសត្វ បានឮសំឡេងរបស់ព្រានព្រៃនោះ គិតថា បុរសនេះ ជាមនុស្សប្រាសចាកទីពឹង កាលដែលមានយើងនៅទីនេះ បុរសនេះគប្បីវិនាសក្នុងទីនេះ គឺមិនសមគួរដល់យើងឡើយ ។ គិតដូច្នេះហើយ ទើបដើរសំដៅទៅរកព្រានៗ បានឃើញដំរីក៏រត់ ព្រោះភ័យខ្លាច ។ ព្រះបរមពោធិសត្វ ទើបពោលថា ម្នាលបុរសដ៏ចម្រើន អ្នកមិនមានភ័យព្រោះអាស្រ័យយើងឡើយ អ្នកឈប់រត់ទៅ ព្រោះហេតុអ្វី ទើបអ្នកស្រែកយំក្នុងទីនេះដូច្នេះ ? ព្រានឆ្លើយថា បពិត្រនាយ ខ្ញុំជាមនុស្សវង្វេងផ្លូវ ថ្ងៃនេះជាថ្ងៃទី ៧ ហើយ ។ ព្រះបរមពោធិសត្វ ពោលថា ម្នាលបុរសដ៏ចម្រើន អ្នកកុំភ័យខ្លាចឡើយ យើងនឹងនាំអ្នកឱ្យទៅដល់

ដែនដីនៃមនុស្ស ។ ដូច្នេះហើយទើបឱ្យព្រានអង្គុយលើខ្នងរបស់ខ្លួន នាំចេញពីព្រៃទៅ ។ ចំណែកព្រានជាមនុស្សអាក្រក់ គិតថា យើងទៅកាន់ព្រះនគរហើយ នឹងទូលព្រះរាជា ។ ព្រានបានធ្វើដើមឈើឱ្យជាគ្រឿងសម្គាល់ និងចំណាំភ្នំទាំងឡាយ ហើយចេញទៅកាន់ក្រុងពារាណសី ។

ក្នុងកាលនោះ ដំរីមង្គលរបស់ព្រះរាជា បានធ្វើកាលកិរិយាទៅ ។ ព្រះរាជា បានត្រាស់បង្គាប់ឱ្យវាយស្គរស្រែកប្រកាសថា បើនរណាៗ បានឃើញដំរីមានខ្លួនសមរម្យ សមជាដំរីមង្គលក្នុងទីណាមួយ បុគ្គលនោះចូរប្រាប់ ។ ព្រាននោះ បានចូលទៅគាល់ព្រះរាជា ហើយទូលថា បពិត្រព្រះសម្មតិទេព ខ្ញុំព្រះអង្គបានឃើញស្តេចដំរី មានខ្លួនល្អសស្គុស សមដើម្បីនឹងធ្វើការហ្វឹកហាត់ ខ្ញុំព្រះអង្គនឹងបង្ហាញផ្លូវទៅ សូមព្រះអង្គទ្រង់បញ្ជូននាយហត្ថាចារ្យ ឱ្យទៅជាមួយនឹងទូលព្រះបង្គំជាខ្ញុំចុះ ។ ព្រះរាជាត្រាស់ទទួលពាក្យរបស់នាយព្រានព្រៃហើយ ទើប



ត្រាស់ថា ពួកអ្នកចូរធ្វើព្រាននេះឱ្យជាអ្នកនាំផ្លូវទៅ ចូរនាំមកនូវស្តេចដំរីដែលព្រានព្រៃនេះបាននិយាយហើយ ។ ដូច្នេះហើយ ព្រមដោយព្រានព្រៃនោះ ទើបស្តេចបញ្ជូននាយហត្ថាចារ្យ ព្រមដោយបរិវារដ៏ច្រើន ។ នាយហត្ថាចារ្យ ទៅជាមួយនឹងបុរសជាព្រានព្រៃ ឃើញដំរីព្រះបរមពោធិសត្វ កំពុងតែចូលទៅរកអាហារ ។ ព្រះបរមពោធិសត្វ ឃើញនាយហត្ថាចារ្យហើយអធិដ្ឋានថា ភ័យនេះ ប្រាកដជាកើតឡើងចាកសម្នាក់បុរសអាក្រក់នោះហើយ ចំណែកយើងជាអ្នកមានកម្លាំងច្រើន អាចកម្ចាត់ដំរីបានទាំងពាន់ដំរី កាលដែលក្រោធហើយ អាចនឹងធ្វើពាហនៈរបស់មេទ័ព ព្រមទាំងដែនឱ្យវិនាសទៅបាន ព្រោះដូច្នោះ ថ្ងៃនេះ បើគេយកលំពែងមកចាក់ក្បាលយើង ក៏យើងមិនក្រោធដែរ ។ ដូច្នេះហើយ ព្រះបរមពោធិសត្វ ក៏បង្អោនសីសៈចុះ រួចឈរនៅស្ងៀម ។ នាយហត្ថាចារ្យចុះកាន់ស្រះបទុម ឃើញភាពសម្បូណ៌ក្នុងលក្ខណៈរបស់ព្រះបរមពោធិសត្វនោះ ទើបពោលថា

មកតាមយើងណា៎! អ្នកដ៏ចម្រើន ហើយនាយហត្ថាចារ្យ ក៏ចាប់ប្រមោយ ដែលដូចជាភួងប្រាក់ ធ្វើដំណើរអស់ ៧ ថ្ងៃ ទើបដល់ក្រុងពារាណសី ។

ចំណែកមាតារបស់ព្រះបរមពោធិសត្វ កាលដែលមិនឃើញបុត្រមករកខ្លួន ក៏សោយសោក យំរៀបរាប់ថា ឱ! ប្រាកដជាព្រះរាជានិងមហាមាត្យនៃព្រះរាជា នាំយកកូនរបស់យើងទៅហើយ ឥឡូវនេះ ព្រៃឈើនឹងចម្រើនព្រោះប្រាសចាកនូវបុត្ររបស់យើង ដូច្នេះហើយទើបពោលនូវគាថា ២ គាថា ដែលមានសេចក្ដីថា :

ដើមពោនស្វាផង ដើមខ្លែងគង់ផង ដើមទទឹម និងស្មៅធំឈ្មោះករវរៈផង ក្រអៅឈូកនិងស្រងែផង នឹងដុះទ្រុបទ្រុលហើយ ទាំងដើមកណិការជិតជើងភ្នំ ក៏ នឹងចេញផ្កាដែរ ព្រោះតែដំរីនោះមិននៅ ។

ក្នុងស្រុក ឬក្នុងក្រុងណាមួយ ដែលព្រះរាជា ឬព្រះរាជកុមារណាមួយ មានគ្រឿងអាភរណៈជាវិការ



នៃមាស រមែងចិញ្ចឹមនូវស្ដេចដំរី ដោយដុំនៃភោជនដ្បិតដំរីដែលព្រះរាជាឬព្រះរាជកុមារគង់ហើយ រមែងមិនតក់ស្លុតក្នុងសង្គ្រាម អាចនឹងទម្លុះទម្លាយនូវក្រោះនៃពួកបច្ចាមិត្ត ។

មាតានៃព្រះបរមពោធិសត្វ មិនបានគិតពីខ្លួនឯងដែលអត់មានអ្នកចិញ្ចឹមឡើយ ព្រោះរវល់តែនឹកដល់បុត្ររវើរវាយរាប់ឈើរាប់ព្រៃ និងនឹកដល់អ្នកដែលនាំបុត្ររបស់ខ្លួនទៅនោះ សូមឱ្យចិញ្ចឹមបុត្ររបស់យើងជាស្ដេចដំរីដែលចិញ្ចឹមម្ដាយ ដោយដុំបាយដែលចម្រើនល្អដោយភោជន ជាភោជនសមគួរដល់ព្រះរាជាទៀតផង ។

ចំណែកនាយហត្ថាចារ្យ នៅក្នុងរវាងផ្លូវ ក៏ផ្ញើសាសន៍ទៅដល់ព្រះរាជា ព្រះរាជាបានត្រាស់បង្គាប់ឱ្យតាក់តែងព្រះនគរ ។ នាយហត្ថាចារ្យ នាំព្រះបរមពោធិ-សត្វ ដែលគេប្រោះព្រំដោយគ្រឿងក្រអូប និងប្រដាប់តាក់តែងចូលទៅក្នុងរោងដំរី ដែលរោងដំរីមានចងវាំង-

ននដ៏វិចិត្រ និងចងពិតានដ៏ល្អពីខាងលើ ហើយឱ្យក្រាបទូលដល់ព្រះរាជា ។ ព្រះរាជាទ្រង់នាំភោជនដែលមានរសយ៉ាងប្រណីតផ្សេងៗ មកឱ្យដល់ព្រះបរមពោធិសត្វ ។ ព្រះបរមពោធិសត្វគិតថា យើងព្រាត់ពីម្ដាយហើយ នឹងមិនទទួលបរិភោគនូវអាហារឡើយ ហើយក៏មិនទទួលអាហាររបស់ព្រះរាជា ។ លំដាប់នោះ ព្រះរាជាកាលដែលត្រូវអង្វរព្រះបរមពោធិសត្វ ទើបត្រាស់នូវព្រះគាថាដែលមានសេចក្ដីថា :

ម្នាលដំរី អ្នកចូរទទួលពំនូតភោជនចុះ ម្នាលដំរីអ្នកកុំស្គមឡើយ ម្នាលដំរី រាជកិច្ចទាំងឡាយ មានច្រើន អ្នកនឹងធ្វើនូវរាជកិច្ចទាំងនោះ ។

ព្រះបរមពោធិសត្វ បានស្ដាប់ដូច្នោះហើយ ទើបពោលនូវគាថា ដែលមានសេចក្ដីថា :

មេដំរីនោះ ជាសត្វកំព្រា ខ្វាក់ភ្នែក កាលដែលមិនមានគេដឹកនាំ មុខតែទង្គិចជើងនឹងដង្គត់ឈើ



ហើយដួលនៅ ដោយបែរមុខទៅរកភ្នំចណ្ឌោរណៈជាមិនខាន ។

លំដាប់នោះ ព្រះរាជាកាលដែលនឹងត្រាស់សួរទៅស្ដេចដំរី ទើបត្រាស់នូវព្រះគាថា ដែលមានសេចក្ដីថា :

ម្នាលដំរីដ៏ប្រសើរ មេដំរីខ្វាក់ភ្នែក មិនមានគេដឹកនាំ មុខតែទង្គិចជើងនឹងដង្គត់ឈើ ហើយដួលនៅដោយបែរមុខទៅរកភ្នំចណ្ឌោរណៈនោះ តើត្រូវជាអ្វីនឹងអ្នក ?

ស្ដេចដំរី ជាព្រះបរមពោធិសត្វ ពោលតបដោយព្រះគាថា ដែលមានសេចក្ដីថា :

បពិត្រមហារាជ មេដំរីខ្វាក់ភ្នែក មិនមានគេដឹកនាំ មុខតែទង្គិចជើងនឹងដង្គត់ឈើ ហើយដួលនៅដោយបែរមុខទៅរកភ្នំចណ្ឌោរណៈនោះ ត្រូវជាមាតារបស់ទូលព្រះបង្គំជាខ្ញុំ ។

ព្រះរាជា ទ្រង់ព្រះសណ្ដាប់នូវសេចក្ដីនោះហើយ កាលដែលនឹងត្រាស់ឱ្យលែងនូវស្ដេចដំរី ទើបត្រាស់នូវព្រះគាថា ដែលមានសេចក្ដីថា :

អ្នកទាំងឡាយ ចូរលែងនូវស្ដេចដំរីដ៏ប្រសើរនោះ ដែលជាសត្វចិញ្ចឹមនូវមាតា ចូរឱ្យស្ដេចដំរីបានជួបជុំនឹងមាតា ព្រមទាំងញាតិទាំងពួងចុះ ។

ព្រះបរមពោធិសត្វ ជាស្ដេចដំរីក្នុងព្រៃហិមពាន្ត បានចេញចាកហ្វូង មកចិញ្ចឹមម្ដាយខ្វាក់ភ្នែក ។ បើវៀរចាកព្រះបរមពោធិសត្វហើយ មាតាក៏នឹងអស់ជីវិតពិតពុំខាន ឯព្រះបរមពោធិសត្វ បើវៀរចាកមាតាហើយ ក៏មិនត្រូវការភាពជាធំឡើយ ។ ថ្ងៃនេះ មាតានិងខ្លួនឯងបានអត់អាហារ ៧ ថ្ងៃហើយ ព្រោះហេតុដូច្នេះ ទើបព្រះរាជាទ្រង់ត្រាស់ឱ្យដោះលែងជាប្រញាប់ នូវស្ដេចដំរីជាមហានាគដ៏ប្រសើរ ។

អភិសម្ពុទ្ធគាថា :



**មុត្តោវ ពន្ធនា នាគោ កាសិរាជេន បេសិតោ**
**មុហុត្តំ អស្សសិត្វាន អគមា យេន បព្វតោ។**

ស្ដេចដំរី គ្រាន់តែរួចចាកចំណងភ្លាម ដែលព្រះរាជាដែនកាសីបានបញ្ជូនទៅ សម្រាកខ្លួនតែមួយរំពេច ក៏ដើរសំដៅទៅរកភ្នំ ។

**តតោ សោ និលិនំ គន្ត្វា សីតំ កុញ្ជរសេវិតំ**
**សោណ្ឌាយ ឧទកមាហិត្វា មាតរំ អភិសិញ្ចថ ។**

ស្ដេចដំរីនោះ ចេញទៅអំពីភ្នំនោះ ដើរទៅកាន់ស្រះឈូកជាកន្លែងពួនសំងំដ៏ត្រជាក់ ដែលខ្លួនធ្លាប់សេពអាស្រ័យនៅ ហើយដងទឹកដោយប្រមោយ យកមកស្រោចស្រពមាតា ។

ស្ដេចដំរីនោះ ផុតចាកចំណង បានសម្រាកមួយភ្លែត ហើយសម្ដែងធម៌ដល់ព្រះរាជា ដោយទសពិធរាជធម៌ ហើយថ្វាយឱវាទថា បពិត្រមហារាជ សូមព្រះអង្គកុំជាបុគ្គលប្រមាទឡើយ ។ កាលដែលមហាជន បូជាដោយគ្រឿងសក្ការៈ មានផ្កាកម្រង និងគ្រឿងក្រអូប

ជាដើម ស្តេចដំរី បានចេញចាកពីព្រះនគរ ។ ក្នុងពេលនោះ ព្រះបរមពោធិសត្វជាស្តេចដំរី បានគិតថា យើងមិនទាន់បានឱ្យមាតាយើងបរិភោគ យើងខ្លួនឯងគឺមិនត្រូវបរិភោគឡើយ ដូច្នេះហើយ ទើបហូសទៅកាន់យកមើមឈូកនិងក្រអៅឈូកជាច្រើន ព្រមជាមួយនឹងទឹកពេញប្រមោយ មកកាន់សម្នាក់មាតា ដែលដេកនៅឯគុហាភ្នំ ហើយស្រោចទឹកលើសីសៈរបស់មាតា ដើម្បីឱ្យខ្លួនប្រាណបានសម្ផស្ស ហើយប្រព្រឹត្តទៅបាន ព្រោះអត់អាហារច្រើនថ្ងៃមកហើយ ។ ព្រះបរមសាស្តា កាលដែលព្រះអង្គទ្រង់ធ្វើឱ្យច្បាស់នូវសេចក្តីទាំងអស់នេះ ទើបទ្រង់ត្រាស់នូវព្រះគាថា ២ គាថា ដោយប្រការដូច្នេះឯង ។

ចំណែកមាតារបស់ព្រះបរមពោធិសត្វ គិតថាជាភ្លៀងធ្លាក់ ទើបពោលគាថា ដែលមានសេចក្តីថា :

ភ្លៀងអ្វីហ្នឹង ផ្តេសផ្តាសបង្អុរចុះ ពុំត្រូវតាមកាលសោះ បុត្របង្កើតរបស់យើង ដែលជាអ្នកទំនុក-



បម្រុងយើង ទៅបាត់ហើយតើ ។

លំដាប់នោះ ព្រះបរមពោធិសត្វ ដើម្បីឱ្យម្តាយសប្បាយចិត្ត ទើបពោលនូវគាថា ដែលមានសេចក្តីថា :

បពិត្រអ្នកម៉ែ សូមម៉ែក្រោកឡើង សម្រាន្តធ្វើអ្វីទៀត ខ្ញុំជាបុត្របង្កើតរបស់ម៉ែ ដែលព្រះរាជាដែនកាសី ទ្រង់ប្រកបដោយព្រះប្រាជ្ញាញាណ មានយសបរិវារច្រើន ព្រះអង្គបានដោះលែងកូនមកវិញហើយ សូមម៉ែទទួលចំណីអាហារចុះ ។

មេដំរីសប្បាយចិត្តណាស់ កាលដែលអនុមោទនាដល់ព្រះហឫទ័យល្អរបស់ព្រះរាជា ទើបពោលគាថាចុងក្រោយ ដែលមានសេចក្តីថា :

ព្រះរាជាអង្គណា បានលែងកូនរបស់ខ្ញុំ ដែលជាអ្នកកោតក្រែង ប្រព្រឹត្តឱនលំទោន ចំពោះបុគ្គលចាស់សព្វៗកាល សូមព្រះរាជាអង្គនោះ ញាំងដែនរបស់ពួកអ្នកកាសីឱ្យចម្រើន និងសូមឱ្យព្រះអង្គគង់

ព្រះជន្មនៅអស់កាលដ៏យូរអង្វែងចុះ ។

គ្រានោះ ព្រះរាជាទ្រង់ជ្រះថ្លាក្នុងព្រះគុណរបស់ព្រះបរមពោធិសត្វ ទ្រង់ត្រាស់បង្គាប់ឱ្យសាងរោងដំរីមិនឆ្ងាយពីក្រុងនិលីនិ ទើបទ្រង់ផ្ដើមតាំងនូវភត្តាហារទុកជានិច្ច ដើម្បីព្រះបរមពោធិសត្វ និងមាតា ។ ក្រោយមកកាលដែលមាតាធ្វើកាលកិរិយាទៅហើយ ព្រះបរមពោធិសត្វ ជាស្ដេចដំរីដ៏ប្រសើរ បន្ទាប់ពីទុកដាក់សាកសពមាតាហើយ ក៏បានធ្វើដំណើរទៅកាន់អាស្រមឈ្មោះ **ករណ្ឌកៈ** ដែលទីនោះមានពួកតាបស ៥០០ អង្គ ចុះពីភ្នំហិមពាន្តមក ។ ព្រះបរមពោធិសត្វ បានថ្វាយទាន មានផ្លែឈើផ្សេងៗ ដល់ព្រះតាបសទាំងនោះ ។ ចំណែកព្រះរាជា ទ្រង់បង្គាប់ឱ្យសាងរូបហត្ថិប្បដិមាអំពីដុំសិលាមានរូបប៉ុនព្រះបរមពោធិសត្វ និងឱ្យមហាសក្ការៈប្រព្រឹត្តទៅ ។ ប្រជាជនក្នុងជម្ពូទ្វីប ប្រជុំគ្នាជាប្រចាំឆ្នាំ បានធ្វើបុណ្យឆ្លងរំលឹកគុណស្ដេចដំរីស ។



ព្រះបរមសាស្ដា គ្រាដែលនាំព្រះធម៌ទេសនានេះមកហើយ ទើបត្រាស់ប្រកាសនូវសច្ចៈទាំងឡាយ ហើយទ្រង់ប្រជុំជាតកថា ព្រះរាជាក្នុងគ្រានោះ បានជាអានន្ទក្នុងកាលនេះ បុរសអាក្រក់ជាព្រានព្រៃ បានជាទេវទត្តនាយហត្ថាចារ្យបានជាសារីបុត្រ មេដំរីជាមាតានោះ បានជាព្រះមហាមាយាទេវី ចំណែកស្ដេចដំរីសដ៏ប្រសើរដែលចិញ្ចឹមនូវមាតា គឺ **តថាគត** នេះឯង ជាព្រះសម្មាសម្ពុទ្ធ ។

**(ចប់មាតុបោសកជាតក)**

## អត្ថគួរជ្រាប

ព្រះបរមពោធិសត្វ សូម្បីកើតក្នុងកំណើតសត្វតិរច្ឆាន ក៏នៅមានការតាំងចិត្តគោរពមាតា ដែលមាតានេះ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា ជាអាហុនេយ្យបុគ្គលជាព្រះព្រហ្ម ជាបុព្វទេព និងជាបុព្វាចារ្យរបស់បុត្រ ។

ព្រះបរមពោធិសត្វ បានធ្វើទុកក្នុងចិត្តថា ដែលឈ្មោះថា មាតា គឺជាអ្នកមានឧបការៈច្រើនដល់បុត្រ ។

ព្រះបរមពោធិសត្វ ចិញ្ចឹមមាតាដោយយកចិត្តទុកដាក់ជាទីបំផុត ព្រមទាំងបានថ្វាយទានដល់ព្រះតាបសនៅពេលដែលអត់ពីមាតាទៅ ។

ព្រះបរមពោធិសត្វ មិនធ្វើឱ្យអ្នកមកចាប់ខ្លួនសូម្បីគ្រាន់តែភ័យបន្តិចនោះឡើយ ហាមសេចក្តីក្រោធបំពេញសីលបារមីជាបារមីដ៏ខ្ពង់ខ្ពស់ក្នុងចរិយានេះ ។

ព្រះបរមពោធិសត្វ ជាស្តេចដំរី មានបរិវារច្រើន មានអានុភាពច្រើន មិនគិតដល់អន្តរាយហើយលះបង់ហ្វូង បូជាមាតាដែលជាខេត្តនៃអ្នកមានឧបការៈ ។

ព្រះបរមពោធិសត្វ ឆ្លាតក្នុងប្រយោជន៍ ឈ្លាសក្នុងកិច្ចការ និងមានបញ្ញាសម្តែងធម៌ថ្វាយព្រះរាជា ។

ព្រះបរមពោធិសត្វ ព្យាយាមទាំងកាយទាំងចិត្តមួយជីវិតជាសត្វប្រសើរ ។

ព្រះបរមពោធិសត្វ អត់ធន់ក្នុងការងារ ជាពិសេសអត់ធន់ក្នុងកំហុសរបស់ព្រានព្រៃ ។

ព្រះបរមពោធិសត្វ គោរពសន្យា រក្សាសម្តី



និយាយពាក្យពិតមានប្រយោជន៍ ទាំងមានភាពស្មោះត្រង់រក្សាទុកក្នុងខ្លួន ។

ព្រះបរមពោធិសត្វ អធិដ្ឋានថា បើគេយកលំពែងមកចាក់យើងយ៉ាងណា ក៏យើងមិនក្រោធឡើយ និងអធិដ្ឋានអត់អាហារ ដរាបណា មាតានៅមិនទាន់បានបរិភោគ ។

ព្រះបរមពោធិសត្វ មិនចងសេចក្តីក្រោធថា អ្នកនេះអាក្រក់មិនដឹងគុណ អ្នកនេះចាប់យើងឡើយ ផ្សាយមេត្តាដល់ព្រះរាជា ជួយអ្នកដែលមានទុក្ខ ។

ព្រះបរមពោធិសត្វ មានចិត្តជាកណ្តាលចំពោះការបូជាដោយលាភសក្ការៈជាដើម លុះអត់ពីមាតាក៏ចេញទៅថ្វាយទាន រីករាយជាមួយនឹងពួកព្រះតាបសក្នុងព្រៃ។

ចប់

## នាមពុទ្ធបរិស័ទអ្នកមានឧបការៈ
## ក្នុងការខារធម្មទាន

១. លោកគ្រូ រស់ សូផាត
២. ឧបាសក យន្ត សួន
៣. ឧបាសក គួង លាងផេង
៤. ឧបាសក មួង យេន
៥. ឧបាសក សោម រតនៈ
៦. ឧបាសក អ៊ិត ប្រាំង
៧. ឧបាសិកា ជា សុណារី
៨. ឧបាសិកា ប៊ុត ម៉ាលី
៩. ឧបាសក គុយ សុធន
១០. ឧបាសក វ៉ាន់ ខុនណា
១១. ឧបាសក ម៉ៅ ផុន
១២. ឧបាសក ជឹង វ៉េងអ៊ាវ
១៣. ឧបាសក ង៉ូវ គា
១៤. ឧបាសក ហាយ ចំរើន
១៥. ឧបាសិកា ហួនចាន់បូដា
១៦. ឧបាសិកា ស្រី បូរ៉ាន់
១៧. ឧបាសក គឹម សោភ័ណ
១៨. ឧបាសក ទូច គីមស្រ៊ាង
១៩. ឧបាសិកា ហាយច័ន្ទធរី



## រាយនាមពុទ្ធបរិស័ទក្នុងសហគមន៍ធម្មទាន
## ឧបត្ថម្ភប្រាក់ផ្សព្វផ្សាយព្រះធម៌ប្រចាំឆ្នាំ

១- ឧ.ស. យូស៊ាង ងួនលី និង ឧ.សិ. លីម ឃីម ............. ស.រ.អ.
២- ឧ.ស. ឆាយ អ៊ីវស៊ាង និង ឧ.សិ.ហុង គីមសែ ......... ស.រ.អ.
៣- ឧ.ស. ឆាយអ៊ីវ ស្រេងលីម និង ឧ.សិ.ហួត ឃីម....... ស.រ.អ.
៤- ឧ.ស. ហៃ ប៊ុនណារិន និង ឧ.សិ.អោង ស៊ីថាន់ ......... ស.រ.អ.
៥- ឧ.ស. វង់ ម៉ៅ និង ឧ.សិ.ឆាន់ កាន់ជួង ព្រមទាំងបុត្រ. ស.រ.អ.
៦- ឧ.សិ. ឆាន់ ហៃកឹង ព្រមទាំងបុត្រ និង ចៅ ........... ស.រ.អ.
៧- ឧ.សិ.ប៊ិត ថងខាំ និង ឧ.សិ.សាន ផល្លីន ព្រមទាំងបុត្រ. ស.រ.អ.
៨- ឧ.សិ. ស៊ីវ យក់លុយ .......................................... ស.រ.អ.
៩- ឧ.ស. អ៊ុត ឆៃវ៉ាន និង ឧ.សិ.ធាន ស៊ុនលី និងបុត្រ ..... ស.រ.អ.
១០- ឧបាសិកា អ៊ឹង ស៊ីវន ........................................... ស.រ.អ.
១១- ឧ.ស.ស៊ូ ហុកឡុង និង ឧ.សិ.តាន់ ឈីវហា ............ ស.រ.អ.
១២- ឧ.ស. អៀង ឆាយ និង ឧ.សិ. អៀ កេសរ +បុត្រ ..... ស.រ.អ.
១៣- លោកតា តាន់ ឈីវហា និង លោកយាយ ស៊ូ ចិន្ត្រ .... ស.រ.អ.
១៤- ឧ.សិ. តែ សាយជូ ព្រមទាំងកូនចៅ ...................... ស.រ.អ.
១៥- ឧ.ស.ជិម អេងស្រ៊ន និង ភរិយា ព្រមទាំងបុត្រ ....... ស.រ.អ.

១៦- ពុទ្ធបរិស័ទ ចាន់ នារីសុខ និងក្រុមគ្រួសារ ............... ស.រ.អ.

១៧- ឧ.ស.ឆេងសារឿន ឧ.សិ.លាភ+ឧ.ស.ហ៊ីស៊ុ ឧ.សិ.អាន. ស.រ.អ.

១៨- ឧបាសក តាំង ស៊ុនម៉ាប ..................................... ស.រ.អ.

១៩- លោក ចក់ ឈុន និង អ្នកស្រី វណ្ណារី សុខ ............... ស.រ.អ.

២០- លោកយាយ ពិន សាត ....................................... ស.រ.អ.

២១- លោក ចាន់ ម៉ល់ និងអ្នកស្រី ជា សុផា .................. ស.រ.អ.

២២- ឧ.ស. ជា ស៊ុវត្ថានា និង ឧ.សិ.ឃុន សូនីម៉ា +បុត្រ ..... ស.រ.អ.

២៣- ឧ.សិ.លី ប៉ូលីនស៊ីមប៉ូ ........................................ ស.រ.អ.

២៤- ឧ.ស.ហាក់ ច័ន្ទសុផល និង ឧ.សិ.វ៉ាង ស៊ីណា+បុត្រ.... ស.រ.អ.

២៥- ឧ.ស.ស៊ុន ដារិន និង ឧ.សិ.ទូច ចន្ទី ....................... ស.រ.អ.

២៦- ឧ.ស.ឡៅ ហោ និង ឧ.សិ.ង៉ោ ស៊ូអេង .................. ស.រ.អ.

២៧- ឧ.សិ.តាន់ ភិចជូ ព្រមទាំងបុត្រធីតា និងចៅៗ ......... ស.រ.អ.

២៨- ឧ.សិ.ស្រង់ អៃ និង ឧ.សិ.ស្រង់ ឡេង ................... ស.រ.អ.

២៩- ឧ.សិ.ឧត្តមា ពេជ្រ អូន ..................................... ស.រ.អ.

៣០- ឧ.ស.វ៉ាង សារុំធ និង ឧ.សិ.គង់ ស៊ីណាត +បុត្រ ....... ស.រ.អ.

៣១- ភិក្ខុ ឈួម បូ ( វត្តពន្លឺពុទ្ធចក្រ លោវែល ) .............. ស.រ.អ.

៣២- លោក ពេជ្រ សីហា និងអ្នកស្រី ថាប់ សុរត្ន័ ............. ស.រ.អ.

៣៣- ឧ.ស.ប៊ុត ផល និង ភរិយា ................................... ស.រ.អ.

៣៤- លោកគ្រូធម្មបណ្ឌិត អឿ សៅ ............................. ស.រ.អ.



៣៥- ឧ.ស.ប៊ូ ហោនាង និង ឧ.សិ.អ៊ឹង រីទ្ធារី ព្រមទាំងបុត្រ ស.រ.អ.

៣៦- លោក កេត សេរីភ័ត្រ និង អ្នកស្រី ប៉ុល ហត្ថា.......... ស.រ.អ.

៣៧- ឧ.សិ.ឡុង អ៊ីម ................................................ ស.រ.អ.

៣៨- ឧ.សិ.ច័ន្ទ ប៉ុណ្ណារី............................................... ស.រ.អ.

៣៩- ឧ.សិ.ហោ ប៊ួយ និងឧ.សិ.ហោ មួយ ហៅតាំងហ៊្គិចមួយ .ស.រ.អ.

៤០- លោក សំណាង យឹម និង អ្នកស្រី ឡូរ៉ា យឹម .......... ស.រ.អ.

៤១- ឧ.ស.សៅ ហ៊ាន និង ឧ.សិ.មាស ម៉ូនីកា ព្រមទាំងបុត្រ ស.រ.អ.

៤២- ឧ.ស.អ៊ុក សាមឿន និង ឧ.សិ.វួច អ៊ីម ព្រមទាំងបុត្រ. ស.រ.អ.

៤៣- ឧ.ស.ភឿក វ៉ាន និង ឧ.សិ.ហ៊ូ អាត់ ព្រមទាំងកូនចៅ.. ស.រ.អ.

៤៤- ឧ.សិ.តាំង លេខគៀវ ព្រមទាំងបុត្រ និងចៅ .......... ស.រ.អ.

៤៥- ឧ.សិ.នួន ប៊ិច និង ឧ.សិ.រស់ សុផល ..................... ស.រ.អ.

៤៦- ឧ.ស.ហោ លាន និង ភរិយា ................................ ស.រ.អ.

៤៧- ឧ.ស.អ៊ុន ឆៃគ្រី និង ភរិយា .............................. ស.រ.អ.

៤៨- ឧ.សិ.មិល យ៉ែម និង ឧ.សិ.គួយ ឡេង ................. ស.រ.អ.

៤៩- ឧ.សិ.ហុក ឈិន និង ឧ.សិ.ប្រាក់ អៀត និងកូនចៅ .. ស.រ.អ.

៥០- ឧ.សិ.ប៉ាន់ ពិណ្ណារី និងស្វាមី ព្រមទាំងបុត្រ .............. ស.រ.អ.

៥១- ឧ.សិ.ស៊ុន ឡេង ព្រមទាំងបុត្រ និងចៅ ................ ស.រ.អ.

៥២- លោក សួន សាលាភ និងអ្នកស្រី សួ សកនីន +បុត្រ .. ស.រ.អ.

៥៣- ឧ.ស.កៅ សេក និង ឧ.សិ.យី សាគុណ +បុត្រ+ចៅ .... ស.រ.អ.

៥៤- ឧ.សិ.ឈ គឹមហោ ព្រមទាំងបុត្រ និងចៅ ................ ស.រ.អ.
៥៥- ឧ.សិ.ឡាំង គឹមឆេង ព្រមទាំងបុត្រ ........................ ស.រ.អ.
៥៦- ឧ.សិ.ថោង បូនី និង ស្វាមី ព្រមទាំងបុត្រ ................ ស.រ.អ.
៥៧- ឧ.សិ.លឹម សុខុម ព្រមទាំងបុត្រ .............................ស.រ.អ.
៥៨- ឧ.ស.ពឹង សេងគី និង ឧ.សិ.អ៊ីង ធឿម ព្រមទាំងបុត្រ .ស.រ.អ.
៥៩- ឧ.សិ.ប៉ាន សារិទ្ធ ( ង៉ា ) ព្រមទាំងបុត្រ និងចៅ .........ស.រ.អ.
៦០- ឧ.សិ.ង៉ែត លេន ................................................ ស.រ.អ.
៦១- ភិក្ខុ ឡូញ ផល្លី និង ភិក្ខុ ភឿក បូរ ...................... អូស្ត្រាលី
៦២- ឧ.ស.ប៊ុន ហេង និង ឧ.សិ.ជុំ សុខុម ព្រមទាំងបុត្រ.. អូស្ត្រាលី
៦៣- ឧ.សិ.ឱម លក្ខណា ព្រមទាំងបុត្រធីតា ................ អូស្ត្រាលី
៦៤- ឧ.ស.លឹម ធីនសួ និង ឧ.សិ. អ៊ីង ឆាយហួ +បុត្រ. ... អូស្ត្រាលី
៦៥- ឧ.ស.ប៉ុច រឿត និង ឧ.សិ.ញូង ស៊ាងម៉េង+បុត្រ ..... អូស្ត្រាលី
៦៦- ឧ.សិ. ឈ គឹមស៊ីន និង ក្រុមគ្រួសារ ..................... អូស្ត្រាលី
៦៧- ឧ.សិ. សេង សៀងឈុន ព្រមទាំងបុត្រ .................. អូស្ត្រាលី
៦៨- ឧ.សិ.ស៊ីត ស៊ីវន .............................................. អូស្ត្រាលី
៦៩- ឧ.សិ. អ៊ុក ណារី ព្រមទាំងបុត្រ .......................... អូស្ត្រាលី
៧០- កញ្ញា ស៊ុយ ដាណែត ........................................ អូស្ត្រាលី
៧១- យុវជន ចាន់ ឌីណា .......................................... អូស្ត្រាលី
៧២- ឧ.ស.យ៉ង់ សិន និងឧ.សិ.នន់ ហេង +បុត្រ.............. អូស្ត្រាលី



៧៣- ឧ.ស.សំ សុខគុណ និង ឧ.សិ.លី សៀមហៀង+បុត្រ អូស្ត្រាលី
៧៤- ឧ.ស.សរ ប៊ុនធៀង ព្រមទាំងបុត្រ និងចៅ............. អូស្ត្រាលី
៧៥- ឧ.សិ.នូ ធុច ព្រមទាំងបុត្រ និងចៅ....................... អូស្ត្រាលី
៧៦- យាយ ប្រាក់ខាត់+ឧ.ស.ស៊ិន សាន+ឧ.សិ.សម្បត្តិ គង់ អូស្ត្រាលី
៧៧- ឧ.ស.រស់ សារ៉េន និង ឧ.សិ.គង់ សារឿង + បុត្រ .. អូស្ត្រាលី
៧៨- ឧ.ស.ង៉ូវ ឈីវ និង ឧ.សិ.ហេង ពាស៊ីម+បុត្រនិងចៅ.. អូស្ត្រាលី
៧៩- ឧ.ស.ឃិន ថុងអ៊ាន និង ឧ.សិ.ម៉េង គិមស៊ាន + បុត្រ. អូស្ត្រាលី
៨០- ឧ.ស.សុខ សារឿន និង ឧ.សិ.មោក មី + បុត្រ........ អូស្ត្រាលី
៨១- ឧ.សិ.យុង សុន ព្រមទាំងបុត្រ ............................ អូស្ត្រាលី
៨២- ឧ.ស. លឹម ហុងលី និង ឧ.សិ.ស៊ឹម តេងគី +បុត្រ ..... អូស្ត្រាលី
៨៣- ឧ.ស.ឈិត ទ្រី និង ឧ.សិ.បាន់ ណៃហ៊ាង+បុត្រ+ចៅ .អូស្ត្រាលី
៨៤- ឧ.សិ.ម៉េង ប៊ុនធារី ( ហៅស្រីពៅ ) ..................... អូស្ត្រាលី
៨៥- ឧ.សិ.ជា ឡេង ព្រមទាំងបុត្រ ............................. អូស្ត្រាលី
៨៦- ឧ.ស.សាប់ ភូរិន្ទ .............................................. អូស្ត្រាលី
៨៧- ឧ.ស.ស៊ូ ឃីម និង ឧ.សិ.សៀង តិច ព្រមទាំងបុត្រ . អូស្ត្រាលី
៨៨- លោក ឃឹម ឡេង និង អ្នកស្រី ប៉ុល និច្ចសីល +បុត្រ. អូស្ត្រាលី
៨៩- ឧ.ស.ឡៅ គីមងួន និង ឧ.សិ.ដួង លី ព្រមទាំងបុត្រ.. អូស្ត្រាលី
៩០- លោក ហេង ម៉ូវ និង អ្នកស្រី ចន្ថា ......................... អូស្ត្រាលី
៩១- ឧ.ស.ដែន គង់ហួត និង ឧ.សិ.កាំង គឹមស៊ុន ............ អូស្ត្រាលី

៩២- ឧ.ស.ទា សុង ឧ.សិ.ង៉ោ ចាន់ខេង+ប៉េងជីវ+អ៊ីហ៊ាប . អូស្ត្រាលី

៩៣- ឧ.ស.រាជ ស៊ាង និង ឧ.សិ.វង់ រិទ្ធ ព្រមទាំងបុត្រ ...... អូស្ត្រាលី

៩៤- ឧ.សិ.ឆេង លុន ព្រមទាំងបុត្រ និងចៅ ................. អូស្ត្រាលី

៩៥- Mr ANARING និងអ្នកស្រីកាយ សផា+បុត្រ+បងប្អូន អល្លឺម៉ង់

៩៦- លោក យូណូស អាស៊ីស និងអ្នកស្រី ហុក ណារី+បុត្រ . បារាំង

៩៧- ឧ.ស.ង៉ូវ ជួនណារេត និង ឧ.សិ.ង៉ូវ សោភ័ណ+បុត្រ...... បារាំង

៩៨- ឧ.ស. ឡុក ប៊ុនអ៊ីវ និង ឧ.សិ.តាន់ ស៊ីវឡាង+បុត្រ....... បារាំង

៩៩- ឧ.ស.ជីន ជុង និងភរិយា........................................ បារាំង

១០០- ឧ.ស. ឡៅ សេងជ្រុន និង ឧ.សិ.ផាំង លី ព្រមទាំងបុត្រ..បារាំង

១០១- ឧ.សិ. ជា ម៉ាក់លាង ............................................ បារាំង

១០២- ឧ.ស.ហ្វាន់ វ៉ាន់ហ្វ និង ឧ.សិ.ហ្វាន់ យូលាង +បុត្រ ..... បារាំង

១០៣- ឧ.ស.ឈឹម ហុកអ៊ាន ព្រមទាំងបុត្រ និងចៅ ............ បារាំង

១០៤- ឧ.សិ.គឹម មុយ ព្រមទាំងក្រុមគ្រួសារ ..................... បារាំង

១០៥- ឧ.សិ.ទាវ គឹមហ៊ួន ព្រមទាំងកូនចៅ ........................ បារាំង

